# LOS ANGELES COUNTY

# គម្រោងថែទាំសុខភាពផ្លូវចិត្ត (MHP)

# សៀវភៅណែនាំសម្រាប់អ្នកទទួលបានអត្ថប្រយោជន៍

## សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស


510 S. Vermont Ave

Los Angeles, CA 90020


**តារាងមាតិកា**

ភាសា និងទម្រង់ផ្សេងទៀត ..... 3

ព័ត៌មានទូទៅ ..... 4

ព័ត៌មានអំពីកម្មវិធីធានារ៉ាប់រង MEDI-CAL ..... 7

របៀបប្រាប់ថាប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវការជំនួយ ..... 11

ការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស ..... 14

ការជ្រើសរើសអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ..... 23

វិសាលភាព (កម្រិត) នៃសេវាកម្ម ..... 26

ការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ដោយគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ..... 34

ដំណើរការនៃការដោះស្រាយបញ្ហា៖ ការដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ ឬការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ..... 38

ដំណើរការនៃការប្តឹងអំពីភាពអយុត្តិធម៌ ..... 40

ដំណើរការនៃការប្តឹងឧទ្ធរណ៍ (បែបធម្មតា និងបែបឆាប់រហ័ស) ..... 43

ដំណើរការនៃការឡើងសវនាការថ្នាក់រដ្ឋ ..... 48

សេចក្តីណែនាំទុកជាមុន ..... 51

សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នកទទួលបានអត្ថប្រយោជន៍ ..... 53

# ភាសា និងទម្រង់ផ្សេងទៀត

## ភាសាផ្សេងទៀត

អ្នកអាចទទួលបានសៀវភៅណែនាំសម្រាប់អ្នកទទួលបានអត្ថប្រយោជន៍នេះ (ហៅកាត់ថា សៀវភៅណែនាំ) និងឯកសារផ្សេងៗទៀតដោយមិនគិតថ្លៃជាភាសាផ្សេងទៀត។ សូមទូរស័ព្ទទៅកាន់ Los Angeles Mental Health Plan។ ការហៅទូរស័ព្ទនេះគឺមិនគិតថ្លៃទេ។

## ទម្រង់ផ្សេងទៀត

អ្នកអាចទទួលបានព័ត៌មាននេះដោយមិនគិតថ្លៃ ក្នុងទម្រង់ជំនួយផ្សេងទៀត ដូចជាអក្សរសម្រាប់អ្នកមើលមិនឃើញ (Braille) ឬអក្សរពុម្ពធំទំហំ 18 ឬក៏ជាសម្លេង។ សូមទូរស័ព្ទទៅកាន់ Los Angeles Mental Health ។ ការហៅទូរស័ព្ទនេះគឺមិនគិតថ្លៃទេ។

## សេវាកម្មផ្នែកបកប្រែភាសាផ្ទាល់មាត់

អ្នកមិនចាំបាច់ឱ្យសមាជិកក្រុមគ្រួសារ ឬមិត្តភក្តិធ្វើជាអ្នកបកប្រែនោះទេ។ សេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ ឬផ្នែកភាសា និងផ្នែកវប្បធម៌ដែលមិនគិតថ្លៃ គឺមានផ្តល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ ដើម្បីទទួលបានសៀវភៅណែនាំនេះជាភាសាផ្សេងទៀត ឬដើម្បីទទួលបានជំនួយពីសេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ ឬផ្នែកភាសា និងផ្នែកវប្បធម៌នោះ សូមទូរស័ព្ទទៅកាន់ Los Angeles Mental Health។ ការទូរស័ព្ទនេះគឺមិនគិតថ្លៃទេ។

## ព័ត៌មានទូទៅ

### ហេតុអ្វីបានជាចាំបាច់ត្រូវអានសៀវភៅណែនាំនេះ?

បេសកកម្ម របស់ យើង នៅ នាយកដ្ឋាន Los Angeles County Department of Mental Health គឺ ដើម្បី ផ្តល់ នូវ ក្តី សង្ឃឹម ការ ស្តារ ឡើង វិញ និង សុខុមាល ភាព សម្រាប់ សមាជិក ទាំង អស់ នៃ សហគមន៍ របស់ យើង ។ យើង ជឿ ថា មនុស្ស គ្រប់ គ្នា មាន សិទ្ធិ ក្នុង ការ ថែទាំ សុខភាព ផ្លូវ ចិត្ត ដែល មាន គុណភាព ហើយ ថា សេវា ទាំង នេះ គួរ តែ អាច ចូល ដំណើរ ការ បាន ។ ក្នុង នាម បុគ្គលិក និង ដៃ គូ សហគមន៍ រាប់ ពាន់ នាក់ ដែល ធ្វើ ឲ្យ ការ ថែ ទាំ នេះ អាច ធ្វើ ទៅ បាន ជា រៀង រាល់ ថ្ងៃ យើង មាន មោទនភាព ក្នុង ការ គាំទ្រ អ្នក ចំពោះ ដំណើរ នៃ សុខុមាលភាព និង ការ ត ភ្ជាប់ នេះ ។

សៀវភៅណែនាំនេះប្រាប់អ្នកអំពីរបៀបទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់កម្មវិធីធានារ៉ាប់រង Medi-Cal តាមរយៈគម្រោងថែទាំសុខភាពផ្លូវចិត្តនៃខោនធីរបស់អ្នក។ សៀវភៅណែនាំនេះពន្យល់អំពីអត្ថប្រយោជន៍របស់អ្នក និងរបៀបទទួលបានការថែទាំ។ សៀវភៅនេះក៏នឹងឆ្លើយសំណួរជាច្រើនរបស់អ្នកផងដែរ។

អ្នកនឹងស្វែងយល់អំពី៖

- របៀបទទួលបាន* សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស
- អត្ថប្រយោជន៍ណាខ្លះដែលអ្នកអាចទទួលបាន
- អ្វីខ្លះដែលត្រូវធ្វើ ប្រសិនបើអ្នកមានសំណួរ ឬបញ្ហាមួយ
- សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នកដែលជាអ្នកទទួលបានអត្ថប្រយោជន៍ពីកម្មវិធីធានារ៉ាប់រង Medi-Cal

ប្រសិនបើអ្នកមិនបានអានសៀវភៅណែនាំនេះនាពេលឥឡូវនេះទេ អ្នកគួរតែរក្សាទុកសៀវភៅណែនាំនេះដើម្បីអាចអាននៅពេលក្រោយបាន។ សៀវភៅណែនាំនេះ និងឯកសារជាលាយលក្ខណ៍អក្សរផ្សេងទៀតអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិកនៅលើគេហទំព័រ *[mental health plan URL] ឬក្នុងទម្រង់បោះពុម្ពពីគម្រោងថែទាំសុខភាពផ្លូវចិត្តដោយមិនគិតថ្លៃទេ។ សូមទូរស័ព្ទទៅគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតាមរយៈលេខ *[mental health plan to Enter Toll-Free Phone Number Here if Different Than Footer] ប្រសិនបើអ្នកចង់បានច្បាប់ចម្លងជាលក្ខណៈបោះពុម្ព។

សូមប្រើប្រាស់សៀវភៅណែនាំនេះជាឯកសារបន្ថែមលើព័ត៌មានដែលអ្នកបានទទួល នៅពេលដែលអ្នកចុះឈ្មោះនៅក្នុងកម្មវិធីធានារ៉ាប់រង Medi-Cal  នោះ។

### ត្រូវការសៀវភៅណែនាំនេះជាភាសារបស់អ្នក ឬទម្រង់ផ្សេងទៀត ដែរឬទេ?

ប្រសិនបើអ្នកនិយាយភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេសនោះ សេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ដែលមិនគិតថ្លៃ គឺមានផ្តល់ជូនដល់អ្នក។ សូមទូរស័ព្ទទៅ Los Angeles Mental Healthតាមរយៈលេខ 1-800-854-7771, TTY 771។ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកមានបម្រើការជូន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។

អ្នកក៏អាចទាក់ទងទៅគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតាមរយៈលេខ *[mental health plan to Insert Toll-Free Phone Number(s)] ប្រសិនបើអ្នកចង់ទទួលបានសៀវភៅណែនាំនេះ ឬឯកសារជាលាយលក្ខណ៍អក្សរដទៃទៀតក្នុងទម្រង់ផ្សេង ដូចជាអក្សរពុម្ពធំ ឬអក្សរសម្រាប់អ្នកមើលមិនឃើញ (Braille) ឬក៏ជាសម្លេង។ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជួយអ្នក។

ប្រសិនបើអ្នកចង់បានសៀវភៅណែនាំនេះ ឬឯកសារជាលាយលក្ខណ៍អក្សរដទៃទៀតជាភាសាផ្សេងក្រៅពីភាសាអង់គ្លេសនោះ សូមទូរស័ព្ទទៅគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក។ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជួយដល់អ្នកបានដោយប្រើប្រាស់ភាសារបស់អ្នក នៅពេលនិយាយតាមទូរស័ព្ទ។

ព័ត៌មាននេះមានផ្តល់ជូនជាភាសាផ្សេងៗដូចដែលបានរាយរាប់ខាងក្រោម។

- *[Mental health plan to List Prevalent Languages]

**តើគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់ខ្ញុំទទួលខុសត្រូវចំពោះអ្វីខ្លះ?**

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកទទួលខុសត្រូវចំពោះចំណុចទាំងឡាយ ដូចខាងក្រោម៖

- រកមើលថាតើអ្នកស្របតាមល័ក្ខខ័ណ្ឌដើម្បីទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសពីខោនធី ឬបណ្តាញអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពឬទេ។
- ការផ្តល់ការវាយតម្លៃដើម្បីកំណត់ថាតើអ្នកត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសឬទេ។
- ការផ្តល់លេខទូរស័ព្ទមិនគិតថ្លៃ ដែលមានការឆ្លើយតប 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយដែលអាចប្រាប់អ្នកអំពីរបៀបទទួលបានសេវាកម្មផ្សេងៗពីគម្រោងថែទាំសុខភាពផ្លូវចិត្ត។ 1-800-854-7771, TTY 771.
- ការមានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពគ្រប់គ្រាន់ដែលនៅជិតអ្នក ដើម្បីធ្វើឱ្យប្រាកដថាអ្នកអាចទទួលបានសេវាកម្មផ្នែកការព្យាបាលសុខភាពផ្លូវចិត្តទាំងឡាយណា ដែលមានចេញថ្លៃចំណាយជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិនបើអ្នកត្រូវការសេវាកម្មទាំងនោះ។
- ការជូនដំណឹង និងការអប់រំអ្នកអំពីសេវាកម្មដែលមានផ្តល់ជូនពីគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក។
- ការផ្តល់ជូនដល់អ្នកនូវសេវាកម្មជាភាសារបស់អ្នក ឬដោយអ្នកបកប្រែផ្ទាល់មាត់ (ប្រសិនបើចាំបាច់) ដោយមិនគិតថ្លៃ និងប្រាប់ដល់អ្នកថាសេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ទាំងនេះគឺមានសម្រាប់ប្រើប្រាស់។
- ការផ្តល់ជូនដល់អ្នកនូវព័ត៌មានជាលាយលក្ខណ៍អក្សរអំពីអ្វីដែលមានសម្រាប់អ្នក ជាភាសាដទៃទៀត ឬជាទម្រង់ផ្សេងទៀតដូចជាអក្សរសម្រាប់អ្នកមើលមិនឃើញ (Braille) ឬក៏ជាការបោះពុម្ពអក្សរទំហំធំ។

*[County to insert additional information about materials in prevalent languages, availability of alternative formats, availability of auxiliary aids and services, etc.]

- ការផ្តល់ជូនដល់អ្នកនូវសេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរដ៏សំខាន់ណាមួយនៅក្នុងព័ត៌មានដែលបានបញ្ជាក់នៅក្នុងសៀវភៅណែនាំនេះ ក្នុងរយៈពេលយ៉ាងហោចណាស់ 30 ថ្ងៃមុនកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ដែលបានគ្រោងទុកសម្រាប់ការផ្លាស់ប្តូរនោះ។ ការផ្លាស់ប្តូរមួយត្រូវបានចាត់ទុកថាសំខាន់ នៅពេលដែលមានការកើនឡើង ឬការថយចុះនៃចំនួន ឬប្រភេទនៃសេវាកម្មដែលមាន ឬក៏ប្រសិនបើមានការកើនឡើង ឬការថយចុះនៃចំនួនអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពក្នុងបណ្តាញ ឬក៏ប្រសិនបើមានការផ្លាស់ប្តូរផ្សេងទៀតដែលនឹងផ្តល់ផលប៉ះពាល់ដល់អត្ថប្រយោជន៍ដែលអ្នកទទួលបានតាមរយៈគម្រោងថែទាំសុខភាពផ្លូវចិត្ត។
- សម្របសម្រួលលើការថែទាំរបស់អ្នកជាមួយនឹងគម្រោង ឬប្រព័ន្ធចែកចាយផ្សេងទៀតតាមតម្រូវការ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរនៃការថែទាំ និងណែនាំក្នុងការបញ្ជូនឈ្មោះសម្រាប់អ្នកទទួលបានអត្ថប្រយោជន៍ ដោយមានការធានាថាមិនមានការបញ្ឈប់ឈ្មោះទៅវិញទៅមក ហើយអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពថ្មីទទួលយកកម្មវិធីថែទាំរបស់អ្នកទទួលបានអត្ថប្រយោជន៍នោះ។

## ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ព័ត៌មានអំពីកម្មវិធីធានារ៉ាប់រង MEDI-CAL

### តើនរណាខ្លះដែលអាចទទួលបាន Medi-Cal?

កត្តាជាច្រើនត្រូវបានប្រើប្រាស់ដើម្បីសម្រេចថា តើធានារ៉ាប់រងសុខភាពប្រភេទណាដែលអ្នកអាចទទួលបានពីកម្មវិធី Medi-Cal។ កត្តាទាំងនេះរួមមាន៖

- អ្នកមានចំណូលប៉ុន្មាន
- អាយុរបស់អ្នក
- អាយុរបស់កុមារទាំងឡាយដែលអ្នកមើលថែទាំ
- ថាតើអ្នកមានផ្ទៃពោះ ពិការភ្នែក ឬក៏ជាជនពិការឬទេ
- ថាតើអ្នកមានធានារ៉ាប់រង Medicare ឬទេ

អ្នកក៏ត្រូវតែរស់នៅក្នុងរដ្ឋ California ផងដែរ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានកម្មវិធីធានារ៉ាប់រង Medi-Cal។ ប្រសិនបើអ្នកគិតថា អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានកម្មវិធីធានារ៉ាប់រង Medi-Cal ហើយនោះ សូមស្វែងយល់អំពីរបៀបដាក់ពាក្យស្នើសុំដូចខាងក្រោម។

### តើខ្ញុំអាចដាក់ពាក្យស្នើសុំ Medi-Cal បានយ៉ាងដូចម្ដេច?

អ្នកអាចដាក់ពាក្យស្នើសុំ Medi-Cal បាន នៅពេលណាមួយក៏បានក្នុងមួយឆ្នាំ។ អ្នកអាចនឹងជ្រើសរើសវិធីមួយក្នុងចំណោមវិធីខាងក្រោមដើម្បីដាក់ពាក្យស្នើសុំ។ អាស័យដ្ឋានជាក់លាក់ និងបណ្ដាញទំនាក់ទំនងសម្រាប់ជម្រើសនីមួយៗអាចរកបាននៅលើគេហទំព័រ http://www.dhcs.ca.gov/services/medi-cal/Pages/CountyOffices.aspx។

- តាមសំបុត្រ៖ ដាក់ពាក្យស្នើសុំ Medi-Cal ជាមួយនឹងកម្មវិធី Single Streamlined Application ដែលមានផ្ដល់ជូនជាភាសាអង់គ្លេស និងភាសាផ្សេងទៀតនៅលើគេហទំព័រ http://www.dhcs.ca.gov/services/medi- cal/eligibility/Pages/SingleStreamApps.aspx។ សូមផ្ញើពាក្យស្នើសុំដែលបានបំពេញហើយនោះ ទៅកាន់ការិយាល័យនៅក្នុងតំបន់របស់អ្នក៖

  Los Angeles County Department of Public Social Services
  2415 W. 6th Street
  Los Angeles, CA 90057

- តាមទូរស័ព្ទ៖ ដើម្បីដាក់ពាក្យស្នើសុំតាមទូរស័ព្ទ សូមទូរស័ព្ទទៅកាន់ការិយាល័យខោនធីនៅក្នុងតំបន់របស់អ្នកតាមរយៈ៖ (310) 258-7400

- ដោយផ្ទាល់៖ ដើម្បីដាក់ពាក្យស្នើសុំដោយផ្ទាល់ សូមស្វែងរកការិយាល័យខោនធីនៅក្នុងតំបន់របស់អ្នក

តាមអាស័យដ្ឋាននៅក្នុងតំបន់ដែលមានរាយរាប់ដូចខាងក្រោម។ នៅទីនោះ អ្នកអាចទទួលបានជំនួយក្នុងការបំពេញពាក្យស្នើសុំរបស់អ្នក។ ម្យ៉ាងវិញទៀត ប្រសិនបើអ្នករស់នៅក្នុងខោនធីផ្សេង សូមពិនិត្យមើលគេហទំព័រដែលមានតំណភ្ជាប់ខាងលើ។

Los Angeles County Department of Public Social Services
2415 W. 6th Street
Los Angeles, CA 90057

- តាមអនឡាញ៖ ដាក់ពាក្យស្នើសុំតាមអនឡាញ តាមរយៈគេហទំព័រ www.benefitscal.com ឬគេហទំព័រ www.coveredca.com។
  ពាក្យស្នើសុំទាំងឡាយនឹងត្រូវបានបញ្ជូនប្រកបដោយសុវត្ថិភាពដោយផ្ទាល់ទៅកាន់ការិយាល័យសេវាកម្មសង្គមខោនធីនៅក្នុងតំបន់របស់អ្នក ពីព្រោះកម្មវិធីធានារ៉ាប់រង Medi-Cal គឺមានផ្តល់ជូននៅតាមកម្រិតខោនធី។

Los Angeles County Department of Public Social Services
2415 W. 6th Street
Los Angeles, CA 90057

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យស្នើសុំ ឬមានសំណួរផ្សេងៗ អ្នកអាចទាក់ទងទៅកាន់អ្នកប្រឹក្សាផ្នែកការចុះឈ្មោះដែលបានទទួលការបណ្តុះបណ្តាល (CEC) ដោយមិនគិតថ្លៃបាន។ សូមទូរស័ព្ទទៅកាន់លេខ **1-800-300-1506** ឬស្វែងរក CEC ម្នាក់នៅក្នុងតំបន់តាមរយៈគេហទំព័រ https://apply.coveredca.com/hix/broker/search។

ប្រសិនបើអ្នកនៅតែមានសំណួរផ្សេងៗអំពីកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អ្នកអាចស្វែងយល់បន្ថែមបានតាមរយៈគេហទំព័រ http://www.dhcs.ca.gov/individuals/Pages/Steps-to-Medi-Cal.aspx។

## តើសេវាកម្មសង្គ្រោះបន្ទាន់គឺជាអ្វី?

សេវាកម្មសង្គ្រោះបន្ទាន់ គឺជាសេវាកម្មទាំងឡាយសម្រាប់អ្នកទទួលបានអត្ថប្រយោជន៍ដែលជួបប្រទះទៅនឹងបញ្ហាសុខភាពដែលមិននឹកស្មានដល់ រួមមានទាំងបញ្ហាសុខភាពផ្នែកសង្គ្រោះបន្ទាន់ផ្លូវចិត្តផងដែរ។ បញ្ហាសុខភាពសង្គ្រោះបន្ទាន់មានរោគសញ្ញាធ្ងន់ធ្ងរខ្លាំង (អាចរួមមានទាំងការឈឺចាប់ធ្ងន់ធ្ងរ) ដែលមនុស្សជម្មតាអាចរំពឹងដោយសមហេតុផល ថានឹងអាចកើតឡើងនៅពេលណាក៏ដោយ ដូចជា៖

- សុខភាពរបស់បុគ្គលម្នាក់ (ឬសុខភាពរបស់ទារកដែលមិនទាន់កើត) អាចជួបប្រទះនឹងបញ្ហាធ្ងន់ធ្ងរ
- បញ្ហាធ្ងន់ធ្ងរ (មួយឬច្រើន) ជាមួយនឹងមុខងាររបស់រាងកាយ
- បញ្ហាធ្ងន់ធ្ងរ (មួយឬច្រើន) ជាមួយនឹងសរីរាង្គ ឬផ្នែកណាមួយនៃរាងកាយ

បញ្ហាសុខភាពផ្នែកសង្គ្រោះបន្ទាន់ផ្លូវចិត្តកើតឡើងនៅពេលដែលមនុស្សជម្មតាគិតថានរណាម្នាក់៖

- គឺជាគ្រោះថ្នាក់នាពេលបច្ចុប្បន្ននេះ ទៅដល់ខ្លួនគាត់ឬខ្លួននាងផ្ទាល់ ឬក៏អ្នកដ៏ទៃម្នាក់ទៀត ដោយសារតែ

បញ្ហាសុខភាពផ្លូវចិត្ត ឬបញ្ហាសុខភាពផ្លូវចិត្តដែលសង្ស័យថាមាន។

- មិនអាចផ្តល់ ឬបរិភោគអាហារ ឬក៏ស្លៀកពាក់សម្លៀកបំពាក់ ឬរកទីជម្រកបាននាពេលភ្លាមៗនេះ ដោយសារតែបញ្ហាមួយដែលមើលទៅហាក់បីដូចជា បញ្ហាសុខភាពផ្លូវចិត្ត។

មានការចេញថ្លៃចំណាយសម្រាប់សេវាកម្មសង្គ្រោះបន្ទាន់ទាំងឡាយជូនដល់អ្នកទទួលបានអត្ថប្រយោជន៍របស់កម្មវិធីធានារ៉ាប់រង Medi-Cal 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។
ការអនុញ្ញាតទុកជាមុនគឺមិនតម្រូវចាំបាច់សម្រាប់សេវាកម្មសង្គ្រោះបន្ទាន់នោះទេ។ កម្មវិធីធានារ៉ាប់រង Medi-Cal នឹងចេញថ្លៃចំណាយទៅលើបញ្ហាសង្គ្រោះបន្ទាន់ មិនថាបញ្ហានោះគឺដោយសារតែបញ្ហាផ្នែកសុខភាពផ្លូវកាយ ឬផ្នែកសុខភាពផ្លូវចិត្ត (អារម្មណ៍ ឬផ្លូវចិត្ត) នោះទេ។ ប្រសិនបើអ្នកបានចុះឈ្មោះនៅក្នុងកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អ្នកនឹងមិនត្រូវគិតគូថ្លៃចំណាយ សម្រាប់ការទៅកាន់បន្ទប់សង្គ្រោះបន្ទាន់នោះទេ បើទោះបីជាមិនមែនករណីសង្គ្រោះបន្ទាន់ក៏ដោយ។ ប្រសិនបើអ្នកគិតថាអ្នកមានអាសន្ន សូមទូរស័ព្ទទៅកាន់លេខ **911** ឬក៏ទៅមន្ទីរពេទ្យ ឬទីកន្លែងផ្សេងទៀត ដើម្បីទទួលបានជំនួយ។

**តើមានផ្តល់ជូនមធ្យោបាយធ្វើដំណើរ ដែរឬទេ?**

អាចនឹងមានផ្តល់ជូនមធ្យោបាយធ្វើដំណើរផ្នែកថែទាំសុខភាពសម្រាប់ករណីមិនបន្ទាន់ និងមធ្យោបាយធ្វើដំណើរមិនមែនផ្នែកថែទាំសុខភាព សម្រាប់អ្នកទទួលបានអត្ថប្រយោជន៍ពីកម្មវិធីធានារ៉ាប់រង Medi-Cal ណាដែលមិនអាចមានមធ្យោបាយធ្វើដំណើរដោយខ្លួនឯង ហើយនិងអ្នកដែលមានការចាំបាច់ទៅតាមផ្នែកពេទ្យ ក្នុងការទទួលបានសេវាកម្មជាក់លាក់មួយចំនួនដែលមានចេញថ្លៃចំណាយជូនដោយកម្មវិធីធានារ៉ាប់រង Medi-Cal។ ប្រសិនបើអ្នកត្រូវការជំនួយផ្នែកមធ្យោបាយធ្វើដំណើរ សូមទាក់ទងទៅកាន់ គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់អ្នកសម្រាប់ព័ត៌មាន និងជំនួយ។

ប្រសិនបើអ្នកគឺជាសមាជិករបស់កម្មវិធីធានារ៉ាប់រង Medi-Cal ប៉ុន្តែមិនបានចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងមួយទេ ហើយអ្នកត្រូវការមធ្យោបាយធ្វើដំណើរមិនមែនផ្នែកថែទាំសុខភាព អ្នកអាច ទាក់ទងទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត តាមខោនធីរបស់អ្នកសម្រាប់ជំនួយបាន។ នៅពេលដែលអ្នកទាក់ទងទៅកាន់ក្រុមហ៊ុនធ្វើដំណើរ ពួកគេនឹងសាកសួរព័ត៌មានអំពីកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) និងពេលវេលានៃការណាត់ជួបរបស់អ្នក។ ប្រសិនបើអ្នកត្រូវការមធ្យោបាយធ្វើដំណើរផ្នែកថែទាំសុខភាពសម្រាប់ករណីមិនបន្ទាន់នោះ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអាចចេញវេជ្ជបញ្ជាសម្រាប់មធ្យោបាយធ្វើដំណើរផ្នែកថែទាំសុខភាពសម្រាប់ករណីមិនបន្ទាន់បាន ហើយប្រាប់ឱ្យអ្នកអាចទាក់ទងជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកមធ្យោបាយធ្វើដំណើរ ដើម្បីសម្របសម្រួលការធ្វើដំណើររបស់អ្នកទៅ និងមកពីការណាត់ជួប។

**តើខ្ញុំអាចទាក់ទងទៅនរណា ប្រសិនបើខ្ញុំមានគំនិតចង់ធ្វើអត្តឃាត?**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់មានវិបត្តិ
សូមទូរស័ព្ទទៅកាន់បណ្ដាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិសម្រាប់ការទប់ស្កាត់ការធ្វើអត្តឃាត (National Suicide Prevention Lifeline) តាមរយៈលេខ **988** ឬ **1-800-273-TALK (8255)**។
សម្រាប់អ្នករស់នៅក្នុងតំបន់ដែលកំពុងស្វែងរកជំនួយដើម្បីដោះស្រាយវិបត្តិ
និងដើម្បីទទួលបានសេវាកម្មពីកម្មវិធីសុខភាពផ្លូវចិត្តក្នុងតំបន់ សូមទូរស័ព្ទទៅកាន់លេខ 1-800-854-7771, TTY 771

# របៀបប្រាប់ថាប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់  ត្រូវការជំនួយ

## តើខ្ញុំនឹងបានដោយរបៀបណា នៅពេលដែលខ្ញុំត្រូវការជំនួយ?

មនុស្សជាច្រើនមានការលំបាកនៅក្នុងជីវិត ហើយអាចនឹងជួបប្រទះទៅនឹងបញ្ហាសុខភាពផ្លូវចិត្តផ្សេងៗ។ ចំណុចសំខាន់បំផុតដែលត្រូវចងចាំនោះ គឺថាអាចរកជំនួយបាន។ ប្រសិនបើអ្នក ឬសមាជិកក្រុមគ្រួសាររបស់អ្នកមានសិទ្ធិចូលរួមក្នុងកម្មវិធីធានារ៉ាប់រង Medi-Cal ហើយត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្ត អ្នកគួរតែទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទសម្រាប់ការទទួលបានគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតាមរយៈលេខ 1-800-854-7771, TTY 771។ គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់អ្នកក៏អាចជួយអ្នកក្នុងការទាក់ទងទៅគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកបានផងដែរ ប្រសិនបើពួកគេជឿជាក់ថាអ្នក ឬសមាជិកក្រុមគ្រួសារម្នាក់ត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តដែលគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងមិនចេញថ្លៃចំណាយជូនទេនោះ។ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងជួយអ្នកក្នុងការស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលអ្នកអាចនឹងត្រូវការ។

អ្នកគួរតែទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ប្រសិនបើអ្នក ឬសមាជិកក្រុមគ្រួសារម្នាក់មានសញ្ញាមួយ ឬច្រើនដូចខាងក្រោមនេះ៖

- ការបាក់ទឹកចិត្ត (ឬមានអារម្មណ៍អស់សង្ឃឹម មិនមានទីពឹង ឬកើតទុក្ខព្រួយយ៉ាងខ្លាំង ឬក៏មានអារម្មណ៍ថាអ្នកមិនចង់រស់នៅទៀតនោះទេ)
- ការបាត់បង់ចំណាប់អារម្មណ៍លើសកម្មភាពផ្សេងៗ ដែលជាធម្មតាអ្នកចូលចិត្តធ្វើ
- ការសម្រកទម្ងន់ ឬឡើងទម្ងន់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលខ្លី
- ការគេងច្រើនពេក ឬតិចពេក
- ចលនាផ្នែករាងកាយមានសភាពយឺត ឬហួសប្រមាណ
- មានអារម្មណ៍ថាអស់កម្លាំងស្ទើរតែរាល់ថ្ងៃ
- មានអារម្មណ៍ថាខ្លួនមិនមានតម្លៃ ឬមានកំហុសហួសប្រមាណ
- ការលំបាកក្នុងការគិត ការផ្តោតអារម្មណ៍ និង/ឬការធ្វើការសម្រេចចិត្ត
- ការថយចុះនៃតម្រូវការក្នុងការគេង (មានអារម្មណ៍ថា 'បានសម្រាកគ្រប់គ្រាន់' បន្ទាប់ពីគេងបានតែពីរ ឬបីម៉ោង)
- គំនិតដើរលឿនពេកដែលអ្នកតាមមិនទាន់
- និយាយលឿនខ្លាំងណាស់ ឬមិនអាចឈប់និយាយបាន
- ជឿជាក់ថាមានមនុស្សនឹងមកធ្វើបាបខ្លួនអ្នក
- ឮសម្លេងមនុស្ស និង/ឬសូរដែលអ្នកដទៃស្តាប់មិនឮ
- ឃើញរបស់ដែលអ្នកដទៃមើលមិនឃើញ

- មិនអាចទៅធ្វើការ ឬទៅសាលារៀនបាន ដោយសារមានអារម្មណ៍បាក់ទឹកចិត្ត (ឬមានអារម្មណ៍អស់សង្ឃឹម មិនមានទីពឹង ឬកើតទុក្ខព្រួយយ៉ាងខ្លាំង)
- ចំណាយពេលវេលាយ៉ាងយូរ ក្នុងការមិនខ្វល់អំពីអនាម័យផ្ទាល់ខ្លួន (ការសម្អាតខ្លួនឱ្យស្អាត)
- មានបញ្ហាក្នុងការយល់ដឹង និងការមានទំនាក់ទំនងជាមួយនឹងមនុស្ស
- ការដកថយ ឬការដកខ្លួនចេញពីអ្នកដទៃ
- ការយំញឹកញាប់ ហើយដោយមិនមានហេតុផល
- ខឹង  និង 'ផ្ទុះកំហឹងឡើង' ជាញឹកញាប់ ដោយមិនមានហេតុផល
- មានអារម្មណ៍ប្រែប្រួលខ្លាំង
- ភាគច្រើនមានអារម្មណ៍រសាប់រសល់ ឬព្រួយបារម្ភ
- មានអាកប្បកិរិយាដែលអ្នកដទៃហៅថាចម្លែក ឬប្លែក ហើយដែលខុសពីវប្បធម៌ទូទៅរបស់បុគ្គលនោះ

**តើខ្ញុំនឹងបានដោយរបៀបណា នៅពេលដែលកុមារ ឬក្មេងជំទង់ម្នាក់ត្រូវការជំនួយ?**

អ្នកអាចនឹងទាក់ទងទៅកាន់ខ្សែទូរស័ព្ទរបស់ គម្រោងថែទាំសុខភាពផ្លូវចិត្ត អ្នកបាន តាមរយៈលេខ 1-800-854-7771, TTY 771ឬគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង សម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃសម្រាប់កូន ឬក្មេងជំទង់របស់អ្នក ប្រសិនបើអ្នកគិតថាពួកគេកំពុងបង្ហាញសញ្ញាណាមួយនៃបញ្ហាសុខភាពផ្លូវចិត្ត។ ប្រសិនបើកូន ឬក្មេងជំទង់របស់អ្នកមានសិទ្ធិគ្រប់គ្រាន់សម្រាប់ចូលជាសមាជិករបស់កម្មវិធីធានារ៉ាប់រង Medi-Cal ហើយការវាយតម្លៃរបស់គម្រោងថែទាំសុខភាពផ្លូវចិត្ត បង្ហាញថាចាំបាច់ត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសផ្សេងៗដែលមានចេញថ្លៃចំណាយដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត នោះគម្រោងថែទាំសុខភាពផ្លូវចិត្ត នឹងរៀបចំឱ្យកូន ឬក្មេងជំទង់របស់អ្នកទទួលបានសេវាកម្មផ្សេងៗបាន។ គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់អ្នកក៏អាចជួយអ្នកក្នុងការទាក់ទងទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកផងដែរ ប្រសិនបើពួកគេជឿជាក់ថាកុមារ ឬក្មេងជំទង់របស់អ្នកត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តដែលគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងមិនមានចេញថ្លៃចំណាយជូនបាននោះ។ គម្រោងនេះក៏មានផ្តល់សេវាកម្មសម្រាប់ឪពុកម្តាយទាំងឡាយណាដែលមានអារម្មណ៍លើសលប់ក្នុងការធ្វើជាឪពុកម្តាយ ឬដែលមានបញ្ហាសុខភាពផ្លូវចិត្តផងដែរ។

បញ្ជីត្រួតពិនិត្យខាងក្រោមនេះអាចជួយអ្នកធ្វើការវាយតម្លៃថាតើកូនរបស់អ្នកត្រូវការជំនួយ ដូចជាជំនួយផ្នែកសេវាកម្មសុខភាពផ្លូវចិត្តឬទេ។ ប្រសិនបើមានសញ្ញាច្រើនជាងមួយកើតមានឡើង ឬនៅតែបន្តកើតមានឡើងក្នុងរយៈពេលយូរនោះ ចំណុចនេះអាចបង្ហាញពីបញ្ហាដែលមានកម្រិតធ្ងន់ធ្ងរជាងនេះ ហើយដែលតម្រូវចាំបាច់ឱ្យមានជំនួយពីអ្នកមានវិជ្ជាជីវៈ។ ខាងក្រោមនេះគឺជាសញ្ញាមួយចំនួនដែលអាចរកមើលបាន៖

- ពិបាកយ៉ាងខ្លាំងក្នុងការផ្តោតអារម្មណ៍ ឬនៅស្ងៀម ដែលធ្វើឱ្យពួកគេអាចមានគ្រោះថ្នាក់ដល់រាងកាយ ឬបណ្តាលឱ្យមានបញ្ហានៅសាលារៀន
- ការបារម្ភ ឬការភ័យខ្លាចយ៉ាងខ្លាំង ដែលធ្វើឱ្យពិបាកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ

- ការភ័យខ្លាចយ៉ាងលើសលប់ភ្លាមៗដោយមិនមានហេតុផល ដែលជួនកាលអាចមានចង្វាក់បេះដូងលោតញាប់ ឬដកដង្ហើមលឿនៗ ផងដែរ
- មានអារម្មណ៍ក្រៀមក្រំខ្លាំង ឬដកខ្លួនចេញពីអ្នកដទៃរយៈពេលចាប់ពី ពីរសប្តាហ៍ឡើងទៅ ដែលបណ្តាលឱ្យមានបញ្ហាក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ
- អារម្មណ៍ប្រែប្រួលយ៉ាងខ្លាំង ដែលបណ្តាលឱ្យមានបញ្ហានៅក្នុងទំនាក់ទំនង (ជាមួយនឹងអ្នកដទៃ)
- មានការផ្លាស់ប្តូរចំពោះអាកប្បកិរិយាយ៉ាងខ្លាំង
- ការមិនបរិភោគ ការក្អួត ឬការប្រើប្រាស់ថ្នាំបន្ទន់លាមក ដើម្បីធ្វើឱ្យស្រកទម្ងន់
- ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនម្តងហើយម្តងទៀត
- អាកប្បកិរិយាដែលបាត់បង់ម្ចាស់ការយ៉ាងខ្លាំង ហើយដែលអាចប៉ះពាល់ដល់ខ្លួនឯង ឬអ្នកដទៃ
- មានផែនការយ៉ាងម៉ឺងម៉ាត់ ឬព្យាយាមធ្វើបាប ឬសម្លាប់ខ្លួនឯង
- ការវាយតប់ម្តងហើយម្តងទៀត ឬការប្រើប្រាស់អាវុធ ឬមានផែនការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ករបួសស្នាមដល់អ្នកដទៃ

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស

### តើសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសគឺជាអ្វី?

សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស គឺជាសេវាកម្មផ្នែកសុខភាពផ្លូវចិត្តសម្រាប់អ្នកមានបញ្ហាសុខភាពផ្លូវចិត្ត ឬបញ្ហាផ្លូវអារម្មណ៍ដែលគ្រូពេទ្យទូទៅមិនអាចព្យាបាលបាន។ ជំងឺ ឬបញ្ហាទាំងនេះមានសភាពធ្ងន់ធ្ងរដល់កម្រិតដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់មនុស្សម្នាក់ក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ។ សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរួមមានៈ

- សេវាកម្មផ្នែកសុខភាពផ្លូវចិត្ត
- សេវាកម្មជំនួយផ្នែកថ្នាំ
- ការគ្រប់គ្រងករណីដែលមានគោលដៅ
- សេវាកម្មផ្នែកអន្តរាគមន៍សម្រាប់វិបត្តិ
- សេវាកម្មផ្នែករក្សាស្ថេរភាពទៅនឹងវិបត្តិ
- សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅ សម្រាប់មនុស្សពេញវ័យ
- សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅ សម្រាប់ដោះស្រាយវិបត្តិ
- សេវាកម្មផ្នែកការព្យាបាលកម្រិតខ្លាំង នៅពេលថ្ងៃ
- ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ នៅពេលថ្ងៃ
- សេវាកម្មសម្រាប់អ្នកជំងឺផ្នែកសតិដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- សេវាកម្មមណ្ឌលសុខភាពសម្រាប់ជំងឺផ្នែកសតិ
- សេវាកម្មគាំទ្រពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា (មានសម្រាប់តែមនុស្សពេញវ័យនៅក្នុងខោនធីជាក់លាក់មួយចំនួនតែប៉ុណ្ណោះ ប៉ុន្តែអនីតិជន (ជនមិនទាន់គ្រប់អាយុ) អាចមានសិទ្ធិទទួលបានសេវាកម្មនេះ ដែលជាផ្នែកមួយនៃកម្មវិធីការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល (Early and Periodic Screening, Diagnostic, and Treatment) ដោយមិនគិតអំពីខោនធីដែលពួកគេរស់នៅឡើយ)

បន្ថែមពីលើសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលបានរាយរាប់ខាងលើនេះ អ្នកទទួលបានអត្ថប្រយោជន៍ដែលមានអាយុក្រោម 21 ឆ្នាំមានសិទ្ធិទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តបន្ថែមទៀតដែលជាផ្នែកមួយនៃកម្មវិធី ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាលនេះ។ សេវាកម្មទាំងនោះរួមមានៈ

- សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ
- ការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង
- សេវាកម្មផ្នែកការព្យាបាលអាកប្បកិរិយា
- ការចិញ្ចឹមមើលថែទាំបែបព្យាបាល

ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមអំពីសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនីមួយៗដែលអាចនឹងមានសម្រាប់អ្នក នោះ សូមមើលនៅក្នុងផ្នែក "វិសាលភាព (កម្រិត) នៃសេវាកម្ម" នៅក្នុងសៀវភៅណែនាំនេះ។

**តើខ្ញុំអាចទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសតាមរបៀបណា?**

ប្រសិនបើអ្នកគិតថាអ្នកត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស អ្នកអាចទូរស័ព្ទទៅកាន់
គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ហើយស្នើសុំការណាត់ជួបសម្រាប់ការត្រួតពិនិត្យ
និងការវាយតម្លៃជាលើកដំបូង។ អ្នកអាចទូរស័ព្ទទៅកាន់លេខដែលមិនគិតថ្លៃរបស់ខោនធីអ្នក។
អ្នកក៏អាចស្នើសុំការវាយតម្លៃសម្រាប់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តពី
គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់អ្នកបានផងដែរ
ប្រសិនបើអ្នកគឺជាអ្នកទទួលបានអត្ថប្រយោជន៍នោះ។ ប្រសិនបើ គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង
កំណត់ថាអ្នកស្របតាមលក្ខខ័ណ្ឌនៃការមានសិទ្ធិទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនោះ
គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងនឹងជួយអ្នកក្នុងការផ្លាស់ប្តូរទៅទទួលសេវាកម្មផ្នែកសុខភាពផ្លូវចិត្តតាមរ
យៈ គម្រោងថែទាំសុខភាពផ្លូវចិត្តវិញ។ ជម្រើសណាក៏ដោយគឺមិនខុសនោះទេ
ក្នុងការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្ត។
អ្នកថែមទាំងអាចនឹងទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តដែលមិនមែនឯកទេស
តាមរយៈគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់កម្មវិធីធានារ៉ាប់រង Medi-Cal អ្នក
បន្ថែមពីលើសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសតាមរយៈអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពផ្លូវចិត្តរបស់អ្នកផង
ដែរ ប្រសិនបើអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកកំណត់ថាសេវាកម្មនោះមានលក្ខណៈសមស្របសម្រាប់អ្នក
ហើយដរាបណាសេវាកម្មទាំងឡាយនោះមានការសម្របសម្រួលត្រឹមត្រូវ និងមិនផ្តល់ជូនក្នុងលក្ខណៈដូចគ្នាទេនោះ។

អ្នកក៏អាចនឹងត្រូវបានបញ្ជូនឈ្មោះទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត
របស់អ្នកសម្រាប់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស ដោយមនុស្សម្នាក់ទៀត ឬស្ថាប័នផ្សេងទៀត រួមមានគ្រូពេទ្យ
ឬសាលារៀនរបស់អ្នក សមាជិកក្រុមគ្រួសារម្នាក់ អាណាព្យាបាល
ឬគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងនៃកម្មវិធីធានារ៉ាប់រង Medi-Cal របស់អ្នក
ឬក៏ទីភ្នាក់ងារប្រចាំខោនធីផ្សេងទៀត។ ជាធម្មតា គ្រូពេទ្យរបស់អ្នក
ឬគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់កម្មវិធីធានារ៉ាប់រង Medi-Cal នឹងត្រូវការការអនុញ្ញាតរបស់អ្នក
ឬការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកមើលថែទាំរបស់កុមារ
ដើម្បីធ្វើការបញ្ជូនឈ្មោះដោយផ្ទាល់ទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត លុះត្រាតែនោះគឺជាករណីបន្ទាន់។
គម្រោងថែទាំសុខភាពផ្លូវចិត្ត របស់អ្នកមិនអាចបដិសេធការស្នើសុំធ្វើការវាយតម្លៃជាលើកដំបូង
ដើម្បីកំណត់ថាតើអ្នកស្របតាមលក្ខខ័ណ្ឌសម្រាប់ការទទួលបានសេវាកម្មពីគម្រោងថែទាំសុខភាពផ្លូវចិត្ត
ឬយ៉ាងណានោះទេ។

សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសអាចមានការផ្តល់ជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត (ក្នុងខោនធី)
ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពផ្សេងទៀត ដែលគម្រោងថែទាំសុខភាពផ្លូវចិត្តចុះកិច្ចសន្យាជាមួយ (ដូចជា

គ្លីនិក មណ្ឌលព្យាបាល អង្គការនៅតាមសហគមន៍ ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពសម្រាប់បុគ្គលរៀងៗខ្លួន ជាដើម)។

**តើខ្ញុំអាចទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនៅទីកន្លែងណាខ្លះ?**

អ្នកអាចទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនៅក្នុងខោនធីដែលអ្នករស់នៅ និងនៅខាងក្រៅខោនធីរបស់អ្នក ប្រសិនបើចាំបាច់។ ខោនធីនីមួយៗមានផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសសម្រាប់កុមារ យុវជន មនុស្សពេញវ័យ និងមនុស្សចាស់ ផងដែរ។ ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ អ្នកមានសិទ្ធិទទួលបានការចេញថ្លៃចំណាយ និងអត្ថប្រយោជន៍បន្ថែមទៀត ដែលជាផ្នែកមួយនៃកម្មវិធីការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល  (Early and Periodic Screening, Diagnostic, and Treatment) ។

ប្រសិនបើសមស្របគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក *[mental health plan, if appropriate, may add the language in parenthesis (or one of the providers available through the mental health plan)] នឹងកំណត់ថាតើអ្នកបានស្របតាមល័ក្ខខ័ណ្ឌដើម្បីទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស  ឬទេ។ ប្រសិនបើអ្នកស្របតាមល័ក្ខខ័ណ្ឌមែននោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងបញ្ជូនឈ្មោះអ្នកទៅទទួលការវាយតម្លៃ។ ប្រសិនបើអ្នកមិនស្របតាមល័ក្ខខ័ណ្ឌក្នុងការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសទេ នឹងមានការបញ្ជូនឈ្មោះអ្នកទៅកាន់គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងនៃកម្មវិធីធានារ៉ាប់រង Medi-Cal របស់អ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលមានគិតថ្លៃចំណាយ (fee-for-service provider) ហើយដែលអាចកំណត់ថា តើអ្នកត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តដែលមិនមែនឯកទេសឬយ៉ាងណា។ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពក្នុងនាមជាគម្រោងថែទាំសុខភាពផ្លូវចិត្តបដិសេធ ឬដាក់កំណត់ ឬកាត់បន្ថយ ឬពន្យារពេល ឬក៏បញ្ចប់សេវាកម្មដែលអ្នកចង់បានឬជឿជាក់ថាអ្នកគួរតែទទួលបាននោះ អ្នកមានសិទ្ធិទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ (ដែលហៅថា “សេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍”  (Notice of Adverse Benefit Determination)) ពីគម្រោងថែទាំសុខភាពផ្លូវចិត្ត ដែលជាការជូនដំណឹងដល់អ្នកអំពីហេតុផលនៃការបដិសេធ ហើយនិងសិទ្ធិរបស់អ្នកក្នុងការដាក់បណ្តឹងឧទ្ធរណ៍ (បណ្តឹងបន្ត)  និង/ឬការឡើងសវនាការថ្នាក់រដ្ឋ  (State Hearing)។ អ្នកក៏មានសិទ្ធិក្នុងការមិនយល់ស្របទៅនឹងការសម្រេចចិត្តផងដែរ ដោយការស្នើសុំបណ្តឹងឧទ្ធរណ៍។ អ្នកអាចស្វែងរកព័ត៌មានបន្ថែមខាងក្រោមទាក់ទងទៅនឹងសិទ្ធិរបស់អ្នកចំពោះសេចក្តីជូនដំណឹង និងអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកមិនយល់ស្របទៅនឹងការសម្រេចចិត្តរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនោះ។

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជួយអ្នកក្នុងការស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលអាចផ្តល់ការថែទាំដែលអ្នកត្រូវការបាន។ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែបញ្ជូនឈ្មោះអ្នកទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពណាដែលនៅជិតផ្ទះរបស់អ្នកបំផុត ឬតាមការកំណត់ពេលវេលា និងចម្ងាយដែលនឹងបំពេញតាមតម្រូវការទាំងឡាយរបស់អ្នក។

**តើខ្ញុំអាចទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនៅពេលណា?**

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកត្រូវតែបំពេញតាមការកំណត់ពេលវេលាណាត់ជួបរបស់រដ្ឋ (ស្តេត) នៅពេលកំណត់ការណាត់ជួបសម្រាប់អ្នក ដើម្បីទទួលបានសេវាកម្មផ្នែកថែទាំសុខភាពពីគម្រោងថែទាំសុខភាពផ្លូវចិត្ត។ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែផ្តល់ជូនអ្នកនូវការណាត់ជួបៈ

- ក្នុងអំឡុងពេល 10 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) បន្ទាប់ពីការស្នើសុំដែលមិនបន្ទាន់របស់អ្នក ដើម្បីចាប់ផ្តើមសេវាកម្មជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្ត
- ក្នុងអំឡុងពេល 48 ម៉ោង ប្រសិនបើអ្នកស្នើសុំសេវាកម្មសម្រាប់បញ្ហាបន្ទាន់។
- ក្នុងអំឡុងពេល 15 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) បន្ទាប់ពីការស្នើសុំដែលមិនបន្ទាន់របស់អ្នក សម្រាប់ការណាត់ជួបជាមួយនឹងគ្រូពេទ្យផ្នែកសតិ ហើយនិង
- ក្នុងអំឡុងពេល 10 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) ចាប់តាំងពីការណាត់ជួបលើកមុន សម្រាប់ការព្យាបាលបញ្ហាបន្ត។

ទោះជាយ៉ាងណាក៏ដោយ ពេលវេលារង់ចាំទាំងនេះអាចនឹងយូរជាងនេះទៀត ប្រសិនបើអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកបានកំណត់ថាការរង់ចាំយូរជាងនេះគឺមានភាពសមស្រប ហើយមិនបង្កឱ្យប៉ះពាល់ក្នុងផ្លូវមិនល្អទេនោះ។

**តើនរណាខ្លះជាអ្នកសម្រេចថាខ្ញុំនឹងទទួលបានសេវាកម្មផ្សេងៗ?**

ខ្លួនអ្នកផ្ទាល់ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក និងគម្រោងថែទាំសុខភាពផ្លូវចិត្ត សុទ្ធតែជាប់ពាក់ព័ន្ធក្នុងការសម្រេចចិត្តថា តើសេវាកម្មអ្វីខ្លះដែលអ្នកត្រូវការទទួល តាមរយៈគម្រោងថែទាំសុខភាពផ្លូវចិត្ត។ អ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្តម្នាក់នឹងពិភាក្សាជាមួយនឹងអ្នក ហើយនឹងជួយអ្នកដើម្បីកំណត់ថាតើសេវាកម្មផ្នែកសុខភាពផ្លូវចិត្តប្រភេទណាដែលសមស្របទៅតាមតម្រូវការទាំងឡាយរបស់អ្នកនោះ។

អ្នកមិនចាំបាច់ត្រូវដឹងថា តើអ្នកមានការពិនិត្យលើសុខភាពផ្លូវចិត្ត ឬមានបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់ណាមួយ ដើម្បីស្នើសុំជំនួយនោះទេ។ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងធ្វើការវាយតម្លៃទៅលើបញ្ហារបស់អ្នក។ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនឹងប៉ាន់ប្រមាណមើលថាតើអ្នកអាចនឹងមានបញ្ហាសុខភាពផ្លូវចិត្តដែលជះឥទ្ធិពលអវិជ្ជមានដល់ជីវិតប្រចាំថ្ងៃរបស់អ្នកឬទេ ឬក៏ប្រសិនបើអ្នកអាចនឹងមានបញ្ហាសុខភាពផ្លូវចិត្ត ឬសង្ស័យថាមានបញ្ហាសុខភាពផ្លូវចិត្ត ដែលទំនងជានឹងអាចផ្តល់ផលប៉ះពាល់អវិជ្ជមានទៅដល់ជីវិតរបស់អ្នក ប្រសិនបើអ្នកមិនបានទទួលការព្យាបាលទេនោះ។ អ្នកនឹងអាចទទួលបានសេវាកម្មផ្នែកថែទាំសុខភាពដែលអ្នកត្រូវការ ខណៈពេលដែលអ្នកផ្តល់សេវាកម្មរបស់អ្នកធ្វើការវាយតម្លៃនេះ។ អ្នកមិនចាំបាច់ត្រូវមានការពិនិត្យសុខភាពផ្លូវចិត្ត

ឬមានបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់ណាមួយ
ដើម្បីទទួលបានសេវាកម្មផ្នែកថែទាំសុខភាពក្នុងអំឡុងពេលការវាយតម្លៃនេះ នោះទេ។

ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ អ្នកក៏អាចទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសផងដែរ ប្រសិនបើអ្នកមានបញ្ហាសុខភាពផ្លូវចិត្តដោយសារការទទួលរងរបួសផ្លូវចិត្ត ឬមានការពាក់ព័ន្ធនៅក្នុងប្រព័ន្ធសន្តិសុខរបស់កុមារ ឬមានការពាក់ព័ន្ធនៅក្នុងផ្នែកយុត្តិធម៌របស់អនីតិជន (ជនមិនគ្រប់អាយុ) ឬក៏ជួបប្រទះទៅនឹងភាពមិនមានផ្ទះសម្បែង។ លើសពីនេះទៅទៀត ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែផ្តល់សេវាកម្មដែលជាការចាំបាច់ទៅតាមផ្នែកពេទ្យ ហើយដែលនឹងជួយកែតម្រូវ ឬធ្វើឱ្យស្ថានភាពសុខភាពផ្លូវចិត្តរបស់អ្នកបានប្រសើរឡើង។ សេវាកម្មទាំងឡាយដែលទ្រទ្រង់ គាំទ្រ កែលម្អ ឬធ្វើឱ្យអាចទ្រាំទ្រទៅនឹងបញ្ហាសុខភាពផ្លូវចិត្តបានល្អជាងមុននោះ គឺចាត់ទុកថាជាការចាំបាច់ទៅតាមផ្នែកពេទ្យ។

សេវាកម្មមួយចំនួនអាចទាមទារការអនុញ្ញាតជាមុនពីគម្រោងថែទាំសុខភាពផ្លូវចិត្ត។ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែប្រើប្រាស់អ្នកមានវិជ្ជាជីវៈដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យចំពោះការអនុញ្ញាតទៅលើការផ្តល់សេវាកម្ម។ ដំណើរការពិនិត្យនេះគឺហៅថា ការអនុញ្ញាតជាមុនសម្រាប់សេវាកម្មសុខភាពផ្លូវចិត្តឯកទេស។ ដំណើរការនៃការអនុញ្ញាតរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែអនុវត្តតាមពេលវេលាជាក់លាក់មួយចំនួន។ សម្រាប់ការអនុញ្ញាតជាមុនតាមធម្មតា គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែសម្រេចចិត្តដោយផ្អែកទៅលើការស្នើសុំរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឱ្យបានលឿនតាមដែលល័ក្ខខ័ណ្ឌរបស់អ្នកតម្រូវចាំបាច់។ ឧទាហរណ៍ គម្រោងរបស់អ្នកត្រូវតែប្រញាប់ប្រញាល់ធ្វើការសម្រេចចិត្តចំពោះការអនុញ្ញាត និងផ្តល់ការជូនដំណឹងដោយផ្អែកទៅលើពេលវេលាដែលទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់អ្នក ហើយដែលមិនលើសពី 72 ម៉ោងបន្ទាប់ពីការទទួលបានការស្នើសុំដើម្បីផ្តល់សេវាកម្ម ប៉ុន្តែមិនត្រូវលើសពី 14 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ឡើយ បន្ទាប់ពីគម្រោងថែទាំសុខភាពផ្លូវចិត្តបានទទួលសំណើនោះ។

ប្រសិនបើអ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកស្នើសុំឱ្យបន្ថែមពេលវេលាសេវាកម្ម ឬក៏ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវការទទួលយកព័ត៌មានបន្ថែមពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក និងផ្តល់ហេតុផលត្រឹមត្រូវសម្រាប់ការស្នើសុំនោះ ពេលវេលាអាចនឹងត្រូវបានបន្ថែមរហូតដល់ 14 ថ្ងៃទៀតរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ)។ ឧទាហរណ៍មួយនៃករណីដែលប្រហែលជាត្រូវការការពន្យារពេលនោះ គឺនៅពេលដែលគម្រោងថែទាំសុខភាពផ្លូវចិត្តគិតថាពួកគេអាចនឹងយល់ព្រមទៅលើការស្នើសុំរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពសម្រាប់ការព្យាបាលបាន ប្រសិនបើពួកគេទទួលបានព័ត៌មានបន្ថែមពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តពន្យារពេលវេលាសម្រាប់ការស្នើសុំរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព នោះ ខោនធីនឹងផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរមួយទៅអ្នកអំពីការពន្យារពេលនេះ។

សេវាកម្មទាំងឡាយដែលតម្រូវចាំបាច់ឱ្យមានការអនុញ្ញាតជាមុនរួមមាន៖ សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ (Intensive Home-Based Services) ការព្យាបាលកម្រិតខ្លាំងនៅពេលថ្ងៃ (Day Intensive Treatment Services) ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញនៅពេលថ្ងៃ (Day Rehabilitation) សេវាកម្មផ្នែកការព្យាបាលអាកប្បកិរិយា (Therapeutic Behavioral Services) និងការចិញ្ចឹមមើលថែទាំបែបព្យាបាល (Therapeutic Foster Care)។ អ្នកអាចនឹងសាកសួរទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តសម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការនៃការអនុញ្ញាតជាមុនរបស់គម្រោងនេះ។ សូមទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ដើម្បីស្នើសុំព័ត៌មានបន្ថែម។

ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្ត បដិសេធ ឬពន្យារពេល ឬកាត់បន្ថយ ឬក៏បញ្ចប់សេវាកម្មទាំងឡាយដែលបានស្នើសុំនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit) ដែលនឹងប្រាប់ទៅអ្នកថាសេវាកម្មទាំងឡាយនេះត្រូវបានបដិសេធ ហើយជូនដំណឹងដល់អ្នកថាអ្នកអាចដាក់បណ្តឹងឧទ្ធរណ៍ (បណ្តឹងបន្ត) ហើយនិងផ្តល់ជូនអ្នកនូវព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ។ ដើម្បីស្វែងយល់បន្ថែមអំពីសិទ្ធិរបស់អ្នកក្នុងការដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ ឬដាក់ពាក្យបណ្តឹងឧទ្ធរណ៍ នៅពេលដែលអ្នកមិនយល់ព្រមជាមួយនឹងការសម្រេចចិត្តរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តអ្នក ក្នុងការបដិសេធមិនផ្តល់សេវាកម្មរបស់អ្នក ឬធ្វើសកម្មភាពផ្សេងទៀតដែលអ្នកមិនយល់ព្រមនោះ សូមយោងទៅលើផ្នែក ការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ដោយគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក នៅលើទំព័រទី *[mental health plan to Insert Correct Page Number Prior to Publishing] នៅក្នុងសៀវភៅណែនាំនេះ។

**តើការចាំបាច់ទៅតាមផ្នែកពេទ្យគឺជាអ្វី?**

សេវាកម្មទាំងឡាយដែលអ្នកទទួលបានត្រូវតែជាការចាំបាច់ និងសមស្របទៅតាមផ្នែកពេទ្យ ដើម្បីព្យាបាលបញ្ហារបស់អ្នក។ សម្រាប់បុគ្គលទាំងឡាយដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ សេវាកម្មមួយគឺជាការចាំបាច់ទៅតាមផ្នែកពេទ្យ (medically necessary) នៅពេលដែលសេវាកម្មនោះសមហេតុផល និងចាំបាច់ដើម្បីការពារជីវិតរបស់អ្នក ទប់ស្កាត់ជំងឺឬពិការភាពដែលសំខាន់ ឬក៏កាត់បន្ថយការឈឺចាប់កម្រិតធ្ងន់ធ្ងរ។

សម្រាប់បុគ្គលទាំងឡាយដែលមានអាយុក្រោម 21 ឆ្នាំ សេវាកម្មមួយគឺការចាំបាច់ទៅតាមផ្នែកពេទ្យ ប្រសិនបើសេវាកម្មនោះកែតម្រូវ ឬទ្រទ្រង់ ឬគាំទ្រ ឬកែលម្អ ឬក៏ធ្វើឱ្យអាចទ្រាំទ្រនឹងបញ្ហាសុខភាពផ្លូវចិត្តមួយបានល្អជាងមុន។ សេវាកម្មទាំងឡាយដែលទ្រទ្រង់ ឬគាំទ្រ ឬកែលម្អ ឬក៏ធ្វើឱ្យអាចទ្រាំទ្រនឹងបញ្ហាសុខភាពផ្លូវចិត្តមួយបានល្អជាងមុននោះ គឺចាត់ទុកថាជាការចាំបាច់ទៅតាមផ្នែកពេទ្យ និងមានការចេញថ្លៃចំណាយសេវាកម្មជូន ដែលជាផ្នែកមួយនៃកម្មវិធី សេវាកម្មការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល (Early and Periodic Screening, Diagnostic, and Treatment) ។

**តើខ្ញុំទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តផ្សេងទៀតដែលមិនមានការចេញថ្លៃចំណាយជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត បានយ៉ាងដូចម្តេច?**

ប្រសិនបើអ្នកបានចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង ដោយកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អ្នកមានសិទ្ធិទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺមិនសម្រាកព្យាបាលនៅមន្ទីរពេទ្យ (outpatient) ដូចខាងក្រោមនេះ តាមរយៈគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង ដោយកម្មវិធីធានារ៉ាប់រង Medi-Cal របស់អ្នក។

- ការវាយតម្លៃ និងការព្យាបាលបញ្ហាផ្លូវចិត្ត រួមទាំងការព្យាបាលដោយមិនប្រើប្រាស់ថ្នាំពេទ្យជាបុគ្គល ជាក្រុម និងជាគ្រួសារ។
- ការធ្វើតេស្តផ្នែកចិត្តវិទ្យា និងការធ្វើតេស្តផ្នែកចិត្តវិទ្យាសរសៃប្រសាទ នៅពេលណាដែលមានការបញ្ជាក់ក្នុងលក្ខណៈពេទ្យដើម្បីវាយតម្លៃបញ្ហាសុខភាពផ្លូវចិត្ត។
- សេវាកម្មសម្រាប់អ្នកជំងឺដែលមិនសម្រាកព្យាបាលនៅមន្ទីរពេទ្យ ក្នុងគោលបំណងនៃការត្រួតពិនិត្យថ្នាំដែលត្រូវការឱ្យមានវេជ្ជបញ្ជាមួយប្រភេទ ឬច្រើន។
- ការពិគ្រោះយោបល់ផ្នែកសតិ។
- ការប្រើប្រាស់មន្ទីរពិសោធន៍សម្រាប់អ្នកជំងឺមិនសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬថ្នាំ (សូមកត់សម្គាល់ថាថ្នាំភាគច្រើនគឺមានការចេញថ្លៃចំណាយជូន ដែលជាផ្នែកមួយនៃកម្មវិធីរបស់ Medi-Cal មួយដែលមានឈ្មោះថា ការគិតថ្លៃចំណាយសម្រាប់ការផ្តល់សេវាកម្ម (Fee-For-Service)) ឬក៏ឧបករណ៍ប្រើប្រាស់ផ្សេងៗ និងអាហារឬវីតាមីនបំប៉ន។

ដើម្បីទទួលបានសេវាកម្មមួយក្នុងចំណោមសេវាកម្មនានាខាងលើ សូមទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងដោយកម្មវិធីធានារ៉ាប់រង Medi-Cal របស់អ្នកដោយផ្ទាល់។ ប្រសិនបើអ្នកមិនស្ថិតនៅក្នុងគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងដោយកម្មវិធីធានារ៉ាប់រង Medi-Cal ទេនោះ អ្នកអាចនឹងទទួលបានសេវាកម្មទាំងនេះពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពសម្រាប់បុគ្គលម្នាក់ៗ និងគ្លីនិកដែលទទួលយកកម្មវិធីធានារ៉ាប់រង Medi-Cal។ គម្រោងថែទាំសុខភាពផ្លូវចិត្តអាចនឹងជួយអ្នកបានក្នុងការស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬគ្លីនិកដែលអាចជួយអ្នក ឬក៏អាចនឹងផ្តល់ឱ្យអ្នកនូវគំនិតមួយចំនួនអំពីរបៀបស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬគ្លីនិកមួយ។

ឱសថស្ថាន (កន្លែងលក់ថ្នាំ) ណាដែលទទួលយកកម្មវិធីធានារ៉ាប់រង Medi-Cal អាចឱ្យអ្នកទៅបើកយកថ្នាំដែលមានវេជ្ជបញ្ជាដើម្បីព្យាបាលជំងឺសុខភាពផ្លូវចិត្តបាន។ សូមកត់សម្គាល់ថាថ្នាំដែលត្រូវការឱ្យមានវេជ្ជបញ្ជាភាគច្រើន ហើយដែលចែកចាយដោយឱសថស្ថាន គឺមានការចេញថ្លៃចំណាយជូនដែលជាផ្នែកមួយនៃកម្មវិធីការគិតថ្លៃចំណាយសម្រាប់ការផ្តល់សេវាកម្មរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ហើយមិនមែនគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់អ្នកនោះទេ។

**តើខ្ញុំទទួលបានសេវាកម្មរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ផ្សេងទៀត (ការព្យាបាលទូទៅ/Medi-Cal) ដែលមិនមានការចេញថ្លៃចំណាយជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត បានដោយរបៀបណា?**

ប្រសិនបើអ្នកស្ថិតនៅក្នុងគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងនោះ គម្រោងនេះត្រូវទទួលខុសត្រូវក្នុងស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពសម្រាប់អ្នក។ ប្រសិនបើអ្នកមិនបានចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង ហើយអ្នកមាន Medi-Cal "ធម្មតា" ឬហៅថាកម្មវិធី គិតថ្លៃចំណាយសម្រាប់ការផ្តល់សេវាកម្ម (Fee-For-Service) របស់ Medi-Cal ផងដែរនោះ អ្នកអាចទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពណាមួយដែលទទួលយកកម្មវិធីធានារ៉ាប់រង Medi-Cal ក៏បាន។ អ្នកត្រូវតែប្រាប់ទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកថាអ្នកជាសមាជិករបស់កម្មវិធីធានារ៉ាប់រង Medi-Cal មុនពេលអ្នកចាប់ផ្តើមទទួលសេវាកម្មផ្សេងៗ។ បើមិនដូច្នេះទេ អ្នកអាចនឹងត្រូវបង់ថ្លៃសម្រាប់សេវាកម្មទាំងនោះ។

អ្នកអាចនឹងប្រើប្រាស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលនៅក្រៅគម្រោងសុខភាពរបស់អ្នក សម្រាប់សេវាកម្មរៀបចំគ្រួសារ (ដូចជាការពន្យារកំណើតជាដើម) បាន។

**ចុះប្រសិនបើខ្ញុំមានបញ្ហាការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន?**

ប្រសិនបើអ្នកគិតថាអ្នកត្រូវការសេវាកម្មដើម្បីដោះស្រាយបញ្ហាប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន សូមទាក់ទងទៅកាន់ខោនធីរបស់អ្នកតាមរយៈ៖

Los Angeles County Substance Abuse Prevention and Control
1000 Fremont Ave
Alhambra, CA 91803
(844) 804-7500

**ហេតុអ្វីបានជាខ្ញុំអាចនឹងត្រូវការសេវាកម្មសម្រាប់អ្នកជំងឺផ្នែកសតិដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ?**

អ្នកអាចនឹងត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យ ប្រសិនបើអ្នកមានបញ្ហាសុខភាពផ្លូវចិត្ត ឬរោគសញ្ញានានានៃបញ្ហាសុខភាពផ្លូវចិត្តមួយដែលមិនមានសុវត្ថិភាពក្នុងការព្យាបាលនៅទីតាំងផ្តល់ការថែទាំកម្រិតទាប ហើយដោយ សារតែបញ្ហាស្ថានភាពសុខភាពផ្លូវចិត្ត ឬរោគសញ្ញានានានៃបញ្ហាសុខភាពផ្លូវចិត្តនោះ អ្នក៖

- អាចជាគ្រោះថ្នាក់ចំពោះខ្លួនអ្នក ឬអ្នកដទៃ ឬក៏ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសំខាន់ៗ នាពេលបច្ចុប្បន្ននេះ
- មិនអាចផ្គត់ផ្គង់ ឬប្រើប្រាស់ម្ហូបអាហារ សម្លៀកបំពាក់ ឬទីជម្រកបានទេ
- អាចជាហានិភ័យកម្រិតធ្ងន់ធ្ងរដល់សុខភាពរាងកាយរបស់អ្នក
- មានការធ្លាក់ចុះយ៉ាងខ្លាំងនាពេលថ្មីៗនេះចំពោះសមត្ថភាពក្នុងការធ្វើការងារ ដែលជាលទ្ធផលនៃបញ្ហាសុខភាពផ្លូវចិត្តមួយ
- ត្រូវការការវាយតម្លៃផ្នែកសតិ ឬការព្យាបាលដោយប្រើប្រាស់ថ្នាំ ឬក៏ការព្យាបាលផ្សេងទៀតដែលអាចផ្តល់ជូនបានតែនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះ

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

# ការជ្រើសរើសអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព

## តើខ្ញុំអាចស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលខ្ញុំត្រូវការបានដោយរបៀបណា?

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតម្រូវចាំបាច់ត្រូវបង្ហោះបង្ហាញបញ្ជីឈ្មោះរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនាពេលបច្ចុប្បន្ននេះ នៅតាមអនឡាញ។
ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយនាពេលបច្ចុប្បន្ន
ឬចង់ទទួលបានបញ្ជីឈ្មោះរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលថ្មីបំផុតនោះ
សូមចូលទៅកាន់គេហទំព័ររបស់គម្រោងថែទាំសុខភាពផ្លូវចិត្តអ្នកតាមរយៈ /https://dmh.lacounty.gov/pd
ឬទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត តាមរយៈលេខទូរស័ព្ទដែលមិនគិតថ្លៃ។
អ្នកអាចទទួលបានបញ្ជីជាលាយលក្ខណ៍អក្សរ ឬតាមសំបុត្រ ប្រសិនបើអ្នកស្នើសុំមួយច្បាប់។

គម្រោងថែទាំសុខភាពផ្លូវចិត្តអាចនឹងដាក់កម្រិតមួយចំនួនទៅលើជម្រើសនៃអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។ នៅពេលអ្នកចាប់ផ្តើមទទួលសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសជាលើកដំបូងនោះ
អ្នកអាចស្នើសុំឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក
ត្រូវតែអនុញ្ញាតឱ្យអ្នកផ្លាស់ប្តូរអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព។ ប្រសិន
បើអ្នកស្នើសុំផ្លាស់ប្តូរអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនោះ
គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែអនុញ្ញាតឱ្យអ្នកជ្រើសរើសរវាងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពយ៉ាងហោចណាស់ពីរនាក់ តាមលទ្ធភាពដែលអាចធ្វើទៅបាន។

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកទទួលខុសត្រូវក្នុងការធានាថាអ្នកមានលទ្ធភាពទទួលបានការថែទាំទាន់ពេលវេលា និងមានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពគ្រប់គ្រាន់ដែលនៅជិតអ្នក
ដើម្បីឱ្យប្រាកដថាអ្នកអាចទទួលបានសេវាកម្មផ្នែកការព្យាបាលសុខភាពផ្លូវចិត្តដែលចេញថ្លៃចំណាយជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិន បើអ្នកត្រូវការសេវាកម្មទាំងនោះ។ នៅពេលខ្លះ
អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលជាប់កិច្ចសន្យាជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្ត
ជ្រើសរើសមិនផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសបន្តទៀតទេ។
អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តអាចនឹងលែងជាប់កិច្ចសន្យាជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្តបន្តទៀតទេ
ឬលែងទទួលយកអ្នកជំងឺនៃសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ដោយខ្លួនឯង
ឬក៏តាមការស្នើសុំរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តទៀតទេនោះ។ នៅពេលចំណុចនេះកើតឡើង
គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែខិតខំប្រឹងប្រែងដោយស្មោះត្រង់
ដើម្បីផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលម្នាក់ៗដែលកំពុងទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនោះ។
ការជូនដំណឹងដល់អ្នកទទួលបានអត្ថប្រយោជន៍នេះនឹងផ្តល់ជូនទៅក្នុងរយៈពេល 30 ថ្ងៃរាប់ក្នុងប្រតិទិន
(គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) មុនកាលបរិច្ឆេទនៃការបញ្ចប់សេវាកម្មតែម្តង ឬ 15 ថ្ងៃរាប់ក្នុងប្រតិទិន
(គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) បន្ទាប់ពីគម្រោងថែទាំសុខភាពផ្លូវចិត្ត

ដឹងថាអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនឹងឈប់ដំណើរការ។ នៅពេលចំណុចនេះកើតឡើង
គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកត្រូវតែអនុញ្ញាតឱ្យអ្នកបន្តទទួលបានសេវាកម្មពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលបានចាកចេញពីគម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិនបើអ្នក
និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនោះយល់ព្រម។ ចំណុចនេះគឺហៅថា "ការបន្តការថែទាំ (continuity of care)"
ហើយនឹងពន្យល់នៅផ្នែកខាងក្រោម។

**តើខ្ញុំអាចបន្តទទួលសេវាកម្មពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំនាពេលបច្ចុប្បន្នរបស់ខ្ញុំបាន ដែរឬទេ?**

ប្រសិនបើអ្នកកំពុងទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តពីគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងដោយកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អ្នកអាចនឹងបន្តទទួលបានការថែទាំពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនោះបាន បើទោះបីជាអ្នកទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកក៏ដោយ
ដរាបណាសេវាកម្មផ្សេងៗមានការសម្របសម្រួលរវាងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយ
ហើយសេវាកម្មទាំងនោះគឺមិនដូចគ្នា។ លើសពីនេះទៅទៀត
ប្រសិនបើអ្នកកំពុងទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរួចហើយពីគម្រោងថែទាំសុខភាពផ្លូវចិត្តមួយផ្សេងទៀត ឬគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រង
ឬក៏អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ជាលក្ខណៈបុគ្គលនោះ អ្នកអាចស្នើសុំ “ការបន្តការថែទាំ (continuity of care)” បាន
ដើម្បីឱ្យអ្នកអាចបន្តទទួលបានការព្យាបាលជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនាពេលបច្ចុប្បន្នរបស់អ្នកបានរហូតដល់ 12 ខែ ក្រោមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួនដូចខាងក្រោម
ប៉ុន្តែមិនមែនមានត្រឹមតែចំណុចទាំងនេះនោះទេ

- អ្នកមានទំនាក់ទំនងស្រាប់ជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលអ្នកកំពុងស្នើសុំនេះ។
- អ្នកត្រូវការបន្តជួបជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនាពេលបច្ចុប្បន្នរបស់អ្នកនេះ ដើម្បីបន្តការព្យាបាលដែលកំពុងតែដំណើរការ ឬពីព្រោះការផ្លាស់ប្តូរទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពថ្មីមួយ នឹងប៉ះពាល់ដល់ស្ថានភាពសុខភាពផ្លូវចិត្តរបស់អ្នក
- អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងស្របតាមតម្រូវការចាំបាច់ទាំងឡាយរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ហើយនិង
- អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពយល់ព្រមទៅនឹងតម្រូវការចាំបាច់ទាំងឡាយរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តសម្រាប់ការចុះកិច្ចសន្យាជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្ត។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## វិសាលភាព (កម្រិត) នៃសេវាកម្ម

ប្រសិនបើអ្នកស្របតាមល័ក្ខខ័ណ្ឌសម្រាប់ការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនោះ សេវាកម្មទាំងឡាយខាងក្រោមនេះគឺមានផ្តល់ជូនដល់អ្នក ដោយផ្អែកទៅលើតម្រូវការរបស់អ្នក។ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកនឹងសហការជាមួយនឹងអ្នក ដើម្បីសម្រេចថាសេវាកម្មណាមួយនឹងដំណើរការបានល្អបំផុតសម្រាប់អ្នក។

### សេវាកម្មផ្នែកសុខភាពផ្លូវចិត្ត (Mental Health Services)

- សេវាកម្មផ្នែកសុខភាពផ្លូវចិត្តគឺជាសេវាកម្មផ្នែកការព្យាបាលជាលក្ខណៈបុគ្គល ជាក្រុម ឬជាគ្រួសារ ដែលជួយដល់មនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត ដើម្បីបង្កើតជំនាញក្នុងការទប់ទល់ទៅនឹងបញ្ហាផ្សេងៗសម្រាប់ការរស់នៅប្រចាំថ្ងៃ។ សេវាកម្មទាំងនេះក៏រួមបញ្ចូលទាំងការងារដែលអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពធ្វើ ដើម្បីជួយឱ្យសេវាកម្មផ្សេងៗបានកាន់តែប្រសើរឡើងសម្រាប់អ្នកទទួលសេវាកម្ម ផងដែរ។ ចំណុចទាំងនេះរួមមាន៖ ការវាយតម្លៃដើម្បីមើលថាតើអ្នកត្រូវការសេវាកម្មឬទេ ហើយដើម្បីមើលថាតើសេវាកម្មកំពុងដំណើរការឬអត់នោះ ក៏ដូចជាការរៀបចំផែនការព្យាបាលដើម្បីសម្រេចគោលបំណងនៃការព្យាបាលផ្នែកសុខភាពផ្លូវចិត្តរបស់អ្នក និងសេវាកម្មជាក់លាក់ដែលនឹងត្រូវផ្តល់ជូន ហើយនិង"ការព្យាបាលបន្ថែម (collateral)" ដែលមានន័យថាការសហការជាមួយនឹងសមាជិកក្រុមគ្រួសារ និងមនុស្សសំខាន់ៗនៅក្នុងជីវិតរបស់អ្នក (ប្រសិនបើអ្នកផ្តល់ការអនុញ្ញាត) ដើម្បីជួយអ្នកក្នុងការរក្សា ឬធ្វើឱ្យសមត្ថភាពរស់នៅប្រចាំថ្ងៃរបស់អ្នកបានប្រសើរឡើង។ សេវាកម្មផ្នែកសុខភាពផ្លូវចិត្តអាចផ្តល់ជូនបាននៅតាមគ្លីនិក ឬការិយាល័យរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព តាមរយៈទូរស័ព្ទ ឬតាមរយៈសេវាកម្មថែទាំសុខភាពពីចម្ងាយ (ដូចជា តាមអនឡាញ) ឬក៏នៅតាមផ្ទះ ឬកន្លែងផ្សេងទៀតនៅក្នុងសហគមន៍។ [County to include any additional information regarding: the amount, duration, and scope of benefits available under the Contract in sufficient detail to ensure that beneficiaries understand the benefits to which they are entitled. (42 C.F.R. § 438.10(g)(2)(iii)).]

### សេវាកម្មជំនួយផ្នែកថ្នាំ (Medication Support Services)

- សេវាកម្មទាំងនេះរួមមាន ការចេញវេជ្ជបញ្ជា ការផ្តល់ឬចាក់ ការចែកចាយ និងការត្រួតពិនិត្យថ្នាំផ្នែកសតិ ហើយនិងការអប់រំទាក់ទងទៅនឹងថ្នាំផ្នែកសតិផងដែរ។ សេវាកម្មជំនួយផ្នែកថ្នាំអាចផ្តល់ជូនបាននៅតាមគ្លីនិក ឬការិយាល័យរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព តាមរយៈទូរស័ព្ទ ឬតាមរយៈសេវាកម្មថែទាំសុខភាពពីចម្ងាយ (ដូចជា តាមអនឡាញ) ឬក៏នៅតាមផ្ទះ ឬកន្លែងផ្សេងទៀតនៅក្នុងសហគមន៍។

### ការគ្រប់គ្រងករណីដែលមានគោលដៅ (Targeted Case Management)

- សេវាកម្មនេះជួយក្នុងការទទួលបានសេវាកម្មនៅក្នុងសហគមន៍ ផ្នែកពេទ្យ ផ្នែកការអប់រំ ផ្នែកសង្គម ផ្នែកត្រៀមយកវិជ្ជាជីវៈ ផ្នែកវិជ្ជាជីវៈ ផ្នែកធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ ឬសេវាកម្មផ្សេងទៀតនៅក្នុងសហគមន៍ នៅពេលដែលសេវាកម្មទាំងនេះអាចពិបាកសម្រាប់អ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្តក្នុងការទទួលបានដោយខ្លួនឯងនោះ។ ការគ្រប់គ្រងករណីដែលមានគោលដៅរួមមាន ការបង្កើតផែនការ ឬការទំនាក់ទំនង ការសម្របសម្រួល និងការបញ្ជូនឈ្មោះ ឬការត្រួតពិនិត្យទៅលើការផ្តល់សេវាកម្ម ដើម្បីធានាថាបុគ្គលនោះអាចទទួលបានសេវាកម្មនិងប្រព័ន្ធផ្តល់សេវាកម្មនោះ ហើយនិងការតាមដានដំណើររបស់គេ ប៉ុន្តែមិនមែនមានត្រឹមតែចំណុចទាំងនេះនោះទេ។

**សេវាកម្មផ្នែកអន្តរាគមន៍សម្រាប់វិបត្តិ (Crisis Intervention Services)**

- សេវាកម្មនេះមានផ្តល់ជូនសម្រាប់ដោះស្រាយស្ថានភាពអាសន្នមួយដែលត្រូវការឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ គោលដៅនៃការអន្តរាគមន៍សម្រាប់វិបត្តិសុខភាពគឺដើម្បីជួយមនុស្សនៅក្នុងសហគមន៍ ដូច្នេះពួកគេមិនចាំបាច់ត្រូវសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យនោះទេ។ ការអន្តរាគមន៍សម្រាប់វិបត្តិសុខភាពអាចមានរយៈពេលរហូតដល់ ប្រាំបីម៉ោង ហើយអាចផ្តល់ជូនបាននៅតាមគ្លីនិក ឬការិយាល័យរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព តាមរយៈទូរស័ព្ទ ឬតាមរយៈសេវាកម្មថែទាំសុខភាពពីចម្ងាយ (ដូចជា តាមអនឡាញ) ឬក៏នៅតាមផ្ទះ ឬកន្លែងផ្សេងទៀតនៅក្នុងសហគមន៍។

**សេវាកម្មផ្នែករក្សាស្ថេរភាពទៅនឹងវិបត្តិ (Crisis Stablilization Services)**

- សេវាកម្មនេះមានផ្តល់ជូនសម្រាប់ដោះស្រាយស្ថានភាពអាសន្នមួយដែលត្រូវការឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ ស្ថេរភាពទៅនឹងវិបត្តិសុខភាពមានរយៈពេលតិចជាង 24 ម៉ោង ហើយត្រូវតែផ្តល់ជូននៅកន្លែងថែទាំសុខភាព 24 ម៉ោងក្នុងមួយថ្ងៃដែលមានអាជ្ញាប័ណ្ណ ឬតាមរយៈកម្មវិធីអ្នកជំងឺមិនសម្រាកព្យាបាលដែលមានទីតាំងនៅមន្ទីរពេទ្យ ឬក៏នៅកន្លែងរបស់ផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលមានការបញ្ជាក់ត្រឹមត្រូវក្នុងការផ្តល់សេវាកម្មផ្សេងៗផ្នែករក្សាស្ថេរភាពទៅនឹងវិបត្តិសុខភាព។

**សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់មនុស្សពេញវ័យ (Adult Residential Treatment Services)**

- សេវាកម្មទាំងនេះផ្តល់ការព្យាបាលផ្នែកសុខភាពផ្លូវចិត្ត និងការបង្កើតជំនាញសម្រាប់អ្នកដែលកំពុងរស់នៅក្នុងមណ្ឌលដែលមានអាជ្ញាប័ណ្ណទាំងឡាយណា ហើយដែលផ្តល់សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់អ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្ត។ សេវាកម្មទាំងនេះមានផ្តល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ កម្មវិធីធានារ៉ាប់រង Medi-Cal មិនចេញថ្លៃចំណាយទៅលើបន្ទប់ និងអាហារ សម្រាប់ការស្ថិតនៅក្នុងទីកន្លែងផ្តល់សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់មនុស្សពេញវ័យនោះទេ។

**សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់ដោះស្រាយវិបត្តិ (Crisis Residential Services)**

- សេវាកម្មទាំងនេះផ្តល់ការព្យាបាលផ្នែកសុខភាពផ្លូវចិត្ត និងការបង្កើតជំនាញសម្រាប់អ្នកដែលមានវិបត្តិផ្លូវចិត្ត ឬវិបត្តិផ្នែកអារម្មណ៍កម្រិតធ្ងន់ធ្ងរ ប៉ុន្តែមិនមែនអ្នកដែលត្រូវការឱ្យមានការថែទាំនៅក្នុងមន្ទីរពេទ្យផ្នែកសតិនោះឡើយ។ សេវាកម្មមានផ្តល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍នៅក្នុងមណ្ឌលដែលមានអាជ្ញាប័ណ្ណទាំងឡាយ។ កម្មវិធីធានារ៉ាប់រង Medi-Cal មិនចេញថ្លៃចំណាយទៅលើបន្ទប់ និងអាហារ សម្រាប់ការស្ថិតនៅក្នុងទីកន្លែងផ្តល់សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់ដោះស្រាយវិបត្តិនោះទេ។

**សេវាកម្មផ្នែកការព្យាបាលកម្រិតខ្លាំង នៅពេលថ្ងៃ (Day Treatment Intensive Services)**

- នេះគឺជាកម្មវិធីមួយដែលមានលំនាំត្រឹមត្រូវក្នុងការព្យាបាលបញ្ហាផ្លូវចិត្ត ហើយមានផ្តល់ជូនដល់ក្រុមមនុស្សដែលប្រហែលជាត្រូវការស្នាក់នៅក្នុងមន្ទីរពេទ្យ ឬកន្លែងថែទាំ 24 ម៉ោងក្នុងមួយថ្ងៃមួយផ្សេងទៀត ប្រសិនបើមិនធ្វើដូចនេះទេ។ កម្មវិធីនេះមានរយៈពេលយ៉ាងហោចណាស់ បីម៉ោងក្នុងមួយថ្ងៃ។ មនុស្សទាំងឡាយអាចវិលត្រឡប់ទៅផ្ទះរបស់ពួកគេនៅពេលយប់បាន។ កម្មវិធីនេះរួមមានទាំងសកម្មភាពបង្កើតជំនាញ និងការព្យាបាលដោយមិនប្រើប្រាស់ថ្នាំ ព្រមទាំងការព្យាបាលផ្លូវចិត្តដោយមិនប្រើប្រាស់ថ្នាំផងដែរ។

**ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ នៅពេលថ្ងៃ (Day Rehabilitation)**

- នេះគឺជាកម្មវិធីមួយដែលមានលំនាំត្រឹមត្រូវ ហើយដែលត្រូវបានរៀបចំឡើងដើម្បីជួយមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត ក្នុងការរៀន និងបង្កើតជំនាញដើម្បីទប់ទល់ទៅនឹងបញ្ហានិងជំនាញប្រើប្រាស់ក្នុងជីវិត ហើយនិងដើម្បីគ្រប់គ្រងរោគសញ្ញានានានៃបញ្ហាសុខភាពផ្លូវចិត្តឱ្យបានកាន់តែមានប្រសិទ្ធិភាព។ កម្មវិធីនេះមាន រយៈពេលយ៉ាងហោចណាស់ បីម៉ោងក្នុងមួយថ្ងៃ។ កម្មវិធីនេះរួមមានទាំងសកម្មភាពបង្កើតជំនាញ និងការព្យាបាលដោយមិនប្រើប្រាស់ថ្នាំផងដែរ។

**សេវាកម្មសម្រាប់អ្នកជំងឺផ្នែកសតិដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ (Psychiatric Inpatient Hospital Services)**

- ទាំងនេះគឺជាសេវាកម្មផ្សេងៗដែលផ្តល់ជូននៅក្នុងមន្ទីរពេទ្យផ្នែកសតិដែលមានអាជ្ញាប័ណ្ណ ដោយផ្អែកទៅលើការកំណត់របស់អ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណ ថាបុគ្គលនោះតម្រូវចាំបាច់ឱ្យមានការព្យាបាលផ្នែកសុខភាពផ្លូវចិត្តកម្រិតធ្ងន់ធ្ងរ 24 ម៉ោងក្នុងមួយថ្ងៃ។

**សេវាកម្មមណ្ឌលសុខភាពសម្រាប់ជំងឺផ្នែកសតិ (Psychiatric Health Facility Services)**

- សេវាកម្មទាំងនេះផ្តល់ជូននៅក្នុងមណ្ឌលសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណ ហើយដែលមានឯកទេសក្នុងការព្យាបាលជាលក្ខណៈធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ 24 ម៉ោងក្នុងមួយថ្ងៃ ចំពោះបញ្ហាសុខភាពផ្លូវចិត្តកម្រិតធ្ងន់ធ្ងរផ្សេងៗ។

មណ្ឌលថែទាំសុខភាពផ្នែកសតិត្រូវតែមានកិច្ចព្រមព្រៀងជាមួយនឹងមន្ទីរពេទ្យ ឬគ្លីនិកនៅក្បែរនោះ ដើម្បីបំពេញតម្រូវការផ្នែកថែទាំសុខភាពផ្លូវកាយរបស់មនុស្សទាំងឡាយនៅក្នុងមណ្ឌល។

**តើមានសេវាកម្មពិសេសសម្រាប់កុមារ និង/ឬមនុស្សពេញវ័យនៅក្មេងក្រោមអាយុ 21 ឆ្នាំ ដែរឬទេ?**

អ្នកទទួលបានអត្ថប្រយោជន៍ដែលមានអាយុក្រោម 21 ឆ្នាំមានសិទ្ធិទទួលបានសេវាកម្មបន្ថែមពីកម្មវិធីធានារ៉ាប់រង Medi-Cal តាមរយៈអត្ថប្រយោជន៍មួយដែលហៅថា កម្មវិធីការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល (Early and Periodic Screening, Diagnostic, and Treatment)។

ដើម្បីមានសិទ្ធិទទួលបានសេវាកម្មទាំងឡាយពីកម្មវិធីការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាលនេះ អ្នកទទួលបានអត្ថប្រយោជន៍ត្រូវតែស្ថិតនៅក្រោមអាយុ 21 ឆ្នាំ និងមានវិសាលភាព (កម្រិត) Medi-Cal ដែលពេញលេញ។ កម្មវិធី ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល នេះចេញថ្លៃចំណាយលើសេវាកម្មទាំងឡាយណាដែលជាការចាំបាច់ក្នុងការកែតម្រូវ ឬបន្ធូរបន្ថយបញ្ហាសុខភាពផ្នែកអាកប្បកិរិយាណាមួយ។ សេវាកម្មទាំងឡាយណាដែលទ្រទ្រង់ ឬគាំទ្រ ឬកែលម្អ ឬក៏ធ្វើឱ្យអាចទ្រាំទ្រនឹងបញ្ហាសុខភាព ផ្នែកអាកប្បកិរិយាមួយបានល្អជាងមុននោះ គឺចាត់ទុកថាជាជំនួយដល់បញ្ហាសុខភាពផ្លូវចិត្ត ហើយជាលទ្ធផលគឺជាការចាំបាច់ទៅតាមផ្នែកពេទ្យ និងមានការចេញថ្លៃចំណាយក្នុងនាមជាសេវាកម្មដែលជាផ្នែកមួយនៃកម្មវិធី ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល។

ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីសេវាកម្មទាំងឡាយរបស់កម្មវិធី ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាលនេះ សូមទូរស័ព្ទទៅកាន់ *[County to Insert Relevant Information Here] ឬចូលទៅកាន់ គេហទំព័រ ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការពិនិត្យជំងឺ ហើយនិងការព្យាបាល របស់នាយកដ្ឋានសេវាកម្មផ្នែកថែទាំសុខភាព (DHCS)។

សេវាកម្មខាងក្រោមនេះក៏មានផ្តល់ជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្តផងដែរ សម្រាប់កុមារ ក្មេងជំទង់ និងមនុស្សពេញវ័យនៅក្មេងដែលមានអាយុក្រោម 21 ឆ្នាំ៖ សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា ការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ និងសេវាកម្មផ្នែកការចិញ្ចឹមមើលថែទាំបែបព្យាបាល។

**សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា (Therapeutic Behavioral Services)**

សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយាគឺជាការអន្តរាគមន៍ចំពោះការព្យាបាលអ្នកជំងឺដែលមិនសម្រាកព្យាបាលនៅមន្ទីរពេទ្យ ក្នុងរយៈពេលខ្លី សម្រាប់បុគ្គលម្នាក់រៀងៗខ្លួន និងមានកម្រិតខ្លាំង សម្រាប់អ្នកទទួលបានអត្ថប្រយោជន៍ដែលមានអាយុរហូតដល់ 21 ឆ្នាំ។ បុគ្គលទាំងឡាយដែលទទួលសេវាកម្មទាំងនេះមានការរំខានផ្លូវចិត្តកម្រិតធ្ងន់ធ្ងរ ឬក៏កំពុងជួបប្រទះការផ្លាស់ប្តូរឬវិបត្តិជីវិតដ៏តានតឹង ហើយត្រូវការសេវាកម្មជំនួយជាក់លាក់រយៈពេលខ្លីបន្ថែមទៀត ដើម្បីសម្រេចលទ្ធផលដែលបានបញ្ជាក់នៅក្នុងគម្រោងព្យាបាលជាលាយលក្ខណ៍អក្សររបស់ពួកគេ។

សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយាគឺជាប្រភេទនៃសេវាកម្មសុខភាពផ្លូវចិត្តឯកទេសដែលមានផ្តល់ជូនតាមរយៈ គម្រោងថែទាំសុខភាពផ្លូវចិត្តនីមួយៗ ប្រសិនបើអ្នកមានបញ្ហាផ្លូវចិត្តកម្រិតធ្ងន់ធ្ងរ។ ដើម្បីទទួលបានសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា អ្នកត្រូវតែទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្ត និងមានអាយុក្រោម 21 ឆ្នាំ ហើយនិងមានវិសាលភាព (កម្រិត) Medi-Cal ដែលពេញលេញ។

- <u>ប្រសិនបើអ្នកកំពុងរស់នៅក្នុងផ្ទះ</u>
  បុគ្គលិកពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយាអាចធ្វើការមួយទល់នឹងមួយជាមួយអ្នក ក្នុងការកាត់បន្ថយបញ្ហាអាកប្បកិរិយាកម្រិតធ្ងន់ធ្ងរនានា ដើម្បីព្យាយាមកុំឱ្យអ្នកចាំបាច់ត្រូវទៅទទួលការថែទាំកម្រិតខ្ពស់ជាងនេះ ដូចជាតាមមណ្ឌលស្នាក់នៅជាក្រុមសម្រាប់កុមារ និងមនុស្សពេញវ័យនៅក្មេងដែលមានអាយុក្រោម 21 ឆ្នាំ ហើយដែលមានបញ្ហាផ្លូវចិត្តកម្រិតធ្ងន់ធ្ងរផ្សេងៗនោះ។
- <u>ប្រសិនបើអ្នកកំពុងរស់នៅក្នុងមណ្ឌលស្នាក់នៅជាក្រុមសម្រាប់កុមារ និងមនុស្សពេញវ័យនៅក្មេងដែលមាន អាយុក្រោម 21 ឆ្នាំ ហើយដែលមានបញ្ហាផ្លូវចិត្តកម្រិតធ្ងន់ធ្ងរផ្សេងៗនោះ</u>
  បុគ្គលិកពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា អាចធ្វើការជាមួយនឹងអ្នក ដូច្នេះអ្នកអាចផ្លាស់ប្តូរទីកន្លែងទៅទទួលការថែទាំកម្រិតទាបជាងនេះ ដូចជានៅផ្ទះដែលចិញ្ចឹមមើលថែទាំកុមារ ឬត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ។

សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយានឹងជួយអ្នក និងក្រុមគ្រួសារ អ្នកថែទាំ ឬអាណាព្យាបាលរបស់អ្នកក្នុងការរៀនអំពីវិធីថ្មីៗដើម្បីដោះស្រាយបញ្ហាផ្នែកអាកប្បកិរិយា និងវិធីផ្សេងៗក្នុងការបង្កើនប្រភេទអាកប្បកិរិយាទាំងឡាយណាដែលអនុញ្ញាតឱ្យអ្នកទទួលបានជោគជ័យ។ អ្នក និងបុគ្គលិកពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា ហើយនិងក្រុមគ្រួសារ ឬអ្នកថែទាំ ឬក៏អាណាព្យាបាលរបស់អ្នកនឹងធ្វើការរួមគ្នាជាក្រុម ដើម្បីដោះស្រាយអាកប្បកិរិយាទាំងឡាយណាដែលមានបញ្ហា ក្នុងរយៈពេលដ៏ខ្លីមួយ រហូតដល់អ្នកលែងត្រូវការសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយានេះទៀត។ អ្នកនឹងមានគម្រោងអំពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយាដែលនឹងបង្ហាញថាអ្វីដែលអ្នក ឬក្រុមគ្រួសារ ឬអ្នកថែទាំ ឬក៏អាណាព្យាបាល និងបុគ្គលិកពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយារបស់អ្នកនឹងធ្វើក្នុងអំឡុងពេលមានផ្តល់សេវាកម្មផ្នែកព្យាបាលអាកប្បកិរិយា ហើយនៅពេលណា និងកន្លែងដែលនឹងមានសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយានេះកើតឡើង (នៅផ្ទះ ឬនៅកន្លែងផ្សេង)។ បុគ្គលិកពីសេវាកម្មផ្នែកព្យាបាលអាកប្បកិរិយាអាចសហការជាមួយនឹងអ្នកទៅលើចំណុចភាគច្រើនដែលអ្នកទំនងជាត្រូវការជំនួយចំពោះបញ្ហាអាកប្បកិរិយារបស់អ្នក។ នេះរួមមានទាំងនៅផ្ទះរបស់អ្នក នៅផ្ទះអ្នកចិញ្ចឹមមើលថែទាំ នៅមណ្ឌលស្នាក់នៅជាក្រុម នៅសាលារៀន នៅកម្មវិធីព្យាបាលនៅពេលថ្ងៃ និងនៅទីកន្លែងផ្សេងទៀតក្នុងសហគមន៍។

**ការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង (Intensive Care Coordination)**

ការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំងគឺជាសេវាកម្មគ្រប់គ្រងករណីដែលមានគោលដៅ ហើយដែលសម្របសម្រួលការវាយតម្លៃនៃសេវាកម្មផ្សេងៗ ការរៀបចំផែនការថែទាំចំពោះសេវាកម្មផ្សេងៗ

និងការសម្របសម្រួលសេវាកម្មផ្សេងៗ ជូនដល់អ្នកទទួលបានអត្ថប្រយោជន៍ដែលមានអាយុក្រោម 21 ឆ្នាំ និងមានសិទ្ធិទទួលបានវិសាលភាព (កម្រិត) Medi-Cal ដែលពេញលេញ ហើយនិងស្របតាមល័ក្ខខ័ណ្ឌចាំបាច់ទៅតាមផ្នែកពេទ្យសម្រាប់សេវាកម្មនេះ។

ផ្នែកទាំងឡាយនៃសេវាកម្មការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង រួមមានការវាយតម្លៃ ការរៀបចំផែនការនិងការអនុវត្តសេវាកម្ម ការត្រួតពិនិត្យនិងការសម្របសម្រួល ហើយនិងការផ្លាស់ប្តូរ។ មានការផ្តល់ជូនសេវាកម្មផ្នែកការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំងនានាតាមរយៈគោលការណ៍នៃគំរូការអនុវត្តន៍ជាចំណុចសំខាន់រួមបញ្ចូលគ្នា (Integrated Core Practice Model) រួមទាំងការបង្កើតក្រុមកុមារ និងគ្រួសារដើម្បីធានាបាននូវការសម្របសម្រួលនៃទំនាក់ទំនងរវាងកុមារ ក្រុមគ្រួសាររបស់ពួកគេ ហើយនិងប្រព័ន្ធផ្តល់សេវាកម្មដល់កុមារដែលពាក់ព័ន្ធទាំងឡាយ។

ក្រុមកុមារ និងគ្រួសារ (Child and Family Team) រួមមានអ្នកផ្តល់ការគាំទ្រជាផ្លូវការ (ដូចជាអ្នកសម្របសម្រួលការថែទាំ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព និងអ្នកគ្រប់គ្រងករណីពីទីភ្នាក់ងារផ្តល់សេវាកម្មដល់កុមារ) អ្នកផ្តល់ការគាំទ្រជាធម្មតា (ដូចជាសមាជិកក្រុមគ្រួសារ អ្នកជិតខាង មិត្តភក្តិ និងអ្នកបួសសាសនា) ហើយនិងបុគ្គលផ្សេងទៀតដែល ធ្វើការរួមគ្នាដើម្បីបង្កើត និងអនុវត្តគម្រោងរបស់អតិថិជននេះ ព្រមទាំងទទួលខុសត្រូវចំពោះការគាំទ្រកុមារ និងក្រុមគ្រួសាររបស់ពួកគេក្នុងការសម្រេចបាននូវគោលដៅទាំងឡាយរបស់ពួកគេ។ សេវាកម្មការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង ក៏ផ្តល់ជូននូវ អ្នកសម្របសម្រួលសម្រាប់សេវាកម្មការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង (Intensive Care Coordination Coordinator) ម្នាក់ផងដែរ ដែល៖

- ធានាថាមានការទទួលប្រើប្រាស់ ការសម្របសម្រួល និងការផ្តល់ជូននូវសេវាកម្មដែលចាំបាច់ទៅតាមផ្នែកពេទ្យ ដោយផ្អែកទៅលើចំណុចខ្លាំងសម្រាប់បុគ្គលម្នាក់រៀងៗខ្លួន មានការជំរុញដោយអតិថិជន និងក្នុងលក្ខណៈមួយដែលប្រកបដោយការយល់ដឹងផ្នែកវប្បធម៌ និងភាសា។
- ធានាថាសេវាកម្ម និងជំនួយត្រូវបាននាំមុខដោយតម្រូវការទាំងឡាយរបស់កុមារ។
- ជួយសម្រួលដល់ទំនាក់ទំនងសហការរវាងកុមារ ក្រុមគ្រួសាររបស់ពួកគេ និងប្រព័ន្ធដែលពាក់ព័ន្ធទាំងឡាយ ក្នុងការផ្តល់សេវាកម្មជូនដល់ពួកគេ។
- គាំទ្រដល់ឪពុកម្តាយ/អ្នកថែទាំក្នុងការបំពេញតាមតម្រូវការទាំងឡាយរបស់កូនពួកគេ។
- ជួយបង្កើតក្រុមកុមារ និងគ្រួសារ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់។
- រៀបចំ និងផ្គូផ្គងការថែទាំក្នុងចំណោមអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព និងប្រព័ន្ធផ្តល់សេវាកម្មដល់កុមារ ដើម្បីអនុញ្ញាតឱ្យមានការផ្តល់សេវាកម្មជូនដល់កុមារនៅក្នុងសហគមន៍របស់ពួកគេបាន។

**សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ (Intensive Home-Based Services)**

សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ គឺជាការអន្តរាគមន៍សម្រាប់បុគ្គលម្នាក់រៀងៗខ្លួន និងផ្អែកទៅលើចំណុចខ្លាំង ដែលត្រូវបានបង្កើតឡើងដើម្បីផ្លាស់ប្តូរ ឬធ្វើឱ្យបញ្ហាសុខភាពផ្លូវចិត្តបានប្រសើរឡើង ដែលបញ្ហាទាំងនេះរំខានដល់ដំណើរការរបស់កុមារ/យុវជន ហើយមានគោលបំណងជួយដល់កុមារ/យុវជនក្នុងការកបង្កើតជំនាញចាំបាច់សម្រាប់ដំណើរការប្រកបដោយជោគជ័យនៅផ្ទះ និងក្នុងសហគមន៍ ហើយនិងការកែលម្អសមត្ថភាពរបស់គ្រួសារកុមារ/យុវជន ដើម្បីជួយកុមារ/យុវជនឱ្យដំណើរការដោយជោគជ័យនៅក្នុងផ្ទះ និងក្នុងសហគមន៍ ផងដែរ។

សេវាកម្មទាំងឡាយពីការអន្តរាគមន៍សេវាកម្មកម្រិតខ្លាំងតាមផ្ទះមានផ្តល់ជូនដោយយោងទៅតាមគម្រោងព្យាបាលសម្រាប់បុគ្គលម្នាក់រៀងៗខ្លួន ដែលត្រូវបានបង្កើតឡើងក្រោម គំរូការអនុវត្តន៍ជាចំណុចសំខាន់រួមបញ្ចូលគ្នា (Integrated Core Practice Model) ដោយក្រុមកុមារ និងគ្រួសារ (Child and Family Team) ដោយមានការសម្របសម្រួលជាមួយនឹងគម្រោងសេវាកម្មរួមរបស់គ្រួសារ ដែលអាចនឹងមានការវាយតម្លៃ ការបង្កើតគម្រោង ការព្យាបាល ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើង ហើយនិងការព្យាបាលបន្ថែម ប៉ុន្តែមិនមែនមានត្រឹមតែចំណុចទាំងនេះនោះទេ។ ការអន្តរាគមន៍សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះផ្តល់ជូនដល់អ្នកទទួលបានអត្ថប្រយោជន៍ដែលមានអាយុក្រោម 21 ឆ្នាំ ហើយដែលមានសិទ្ធិទទួលបានវិសាលភាព (កម្រិត) Medi-Cal ដែលពេញលេញ និងស្របតាមល័ក្ខខ័ណ្ឌចាំបាច់ទៅតាមផ្នែកពេទ្យសម្រាប់សេវាកម្មនេះ។

**ការចិញ្ចឹមមើលថែទាំបែបព្យាបាល (Therapeutic Foster Care)**

គំរូនៃសេវាកម្មការចិញ្ចឹមមើលថែទាំបែបព្យាបាលអនុញ្ញាតឱ្យមានការផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលមានរយៈពេលខ្លី កម្រិតខ្លាំង បានយល់អំពីរបួសផ្លូវចិត្ត និងសម្រាប់បុគ្គលម្នាក់រៀងៗខ្លួន ជូនដល់កុមាររហូតដល់អាយុ 21 ឆ្នាំ ដែលមានតម្រូវការផ្នែកផ្លូវចិត្ត និងផ្នែកអាកប្បកិរិយាដែលអាចពិបាកនឹងយល់។ សេវាកម្មទាំងឡាយរួមមានការបង្កើតគម្រោង ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ ហើយនិងការព្យាបាលបន្ថែម (collateral)។ នៅក្នុងសេវាកម្មការចិញ្ចឹមមើលថែទាំបែបព្យាបាលនេះ កុមារទាំងឡាយនឹងឱ្យស្នាក់នៅជាមួយនឹងឪពុកម្តាយចិញ្ចឹមនៃសេវាកម្មការចិញ្ចឹមមើលថែទាំបែបព្យាបាល ដែលមានការបណ្តុះបណ្តាល មានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ហើយនិងមានគាំទ្រ។

**សេវាកម្មដែលមានផ្តល់ជូនតាមទូរស័ព្ទ ឬជាសេវាកម្មថែទាំសុខភាពពីចម្ងាយ**

សេវាកម្មទាំងឡាយដែលអាចផ្តល់ជូនបានតាមរយៈទូរស័ព្ទ ឬជាសេវាកម្មថែទាំសុខភាពពីចម្ងាយ (ដូចជាតាមអនឡាញ)៖

- សេវាកម្មផ្នែកសុខភាពផ្លូវចិត្ត
- សេវាកម្មជំនួយផ្នែកថ្នាំ
- សេវាកម្មផ្នែកអន្តរាគមន៍សម្រាប់វិបត្តិ
- ការគ្រប់គ្រងករណីដែលមានគោលដៅ
- ការសម្របសម្រួលចំពោះការថែទាំកម្រិតខ្លាំង
- សេវាកម្មគាំទ្រពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា

ផ្នែកនៃសេវាកម្មមួយចំនួនអាចត្រូវបានផ្តល់ជូនតាមរយៈទូរស័ព្ទ ឬជាសេវាកម្មថែទាំសុខភាពពីចម្ងាយ (ដូចជាតាមអនឡាញ)៖

- សេវាកម្មផ្នែកការព្យាបាលកម្រិតខ្លាំង នៅពេលថ្ងៃ
- ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញ នៅពេលថ្ងៃ
- សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់មនុស្សពេញវ័យ
- សេវាកម្មផ្នែកការព្យាបាលនៅក្នុងមណ្ឌលដែលមានផ្តល់កន្លែងឱ្យស្នាក់នៅសម្រាប់ដោះស្រាយវិបត្តិ
- សេវាកម្មផ្នែកការរក្សាស្ថេរភាពទៅនឹងវិបត្តិ

សេវាកម្មទាំងឡាយដែលមិនអាចផ្តល់ជូនតាមរយៈទូរស័ព្ទ ឬជាសេវាកម្មថែទាំសុខភាពពីចម្ងាយបាន (ដូចជាតាមអនឡាញ)៖

- សេវាកម្មមណ្ឌលសុខភាពសម្រាប់ជំងឺផ្លូវចិត្ត
- សេវាកម្មសម្រាប់អ្នកជំងឺផ្លូវចិត្តដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- សេវាកម្មផ្នែកការព្យាបាលអាកប្បកិរិយា
- សេវាកម្មកម្រិតខ្លាំងនៅតាមផ្ទះ
- ការចិញ្ចឹមមើលថែទាំបែបព្យាបាល

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ដោយគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក

### តើខ្ញុំមានសិទ្ធិអ្វីខ្លះ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តបដិសេធសេវាកម្មនានាដែលខ្ញុំចង់បាន ឬគិតថាខ្ញុំត្រូវការនោះ?

ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលតាំងនាមជាគម្រោងថែទាំសុខភាពផ្លូវចិត្តនោះ បដិសេធ ឬដាក់កំណត់ ឬកាត់បន្ថយ ឬពន្យារពេល ឬក៏បញ្ចប់សេវាកម្មដែលអ្នកចង់បាន ឬជឿជាក់ថាអ្នកគួរតែទទួលបាននោះ អ្នកមានសិទ្ធិក្នុងការទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមួយ (ហៅថា "សេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination)") ពីគម្រោងថែទាំសុខភាពផ្លូវចិត្ត។ អ្នកក៏មានសិទ្ធិមិនយល់ស្របទៅនឹងការសម្រេចចិត្តផងដែរ ដោយការស្នើសុំការប្តឹងឧទ្ធរណ៍ (ការប្តឹងបន្ត) មួយ។ ផ្នែកនានាខាងក្រោមពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការទទួលបានសេចក្តីជូនដំណឹង និងអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកមិនយល់ស្របទៅនឹងការសម្រេចចិត្តរបសគម្រោងថែទាំសុខភាពផ្លូវចិត្តអ្នកទេនោះ។

### តើការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍គឺជាអ្វី?

ការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Adverse Benefit Determination) គឺមានន័យថា សកម្មភាពណាមួយខាងក្រោមនេះ ដែលធ្វើឡើងដោយគម្រោងថែទាំសុខភាពផ្លូវចិត្តៈ

1. ការបដិសេធ ឬការដាក់កំណត់ទៅលើការអនុញ្ញាតចំពោះសេវាកម្មដែលបានស្នើសុំ រួមទាំងការសម្រេចដោយផ្អែកទៅលើប្រភេទឬកម្រិតនៃសេវាកម្ម ភាពចាំបាច់ទៅតាមផ្នែកពេទ្យ ភាពសមស្រប ទីតាំងឬប្រសិទ្ធិភាពនៃអត្ថប្រយោជន៍ដែលមានចេញថ្លៃចំណាយជូននោះ ផងដែរ។
2. ការកាត់បន្ថយ ឬការផ្អាក ឬក៏ការបញ្ចប់សេវាកម្មដែលមានការអនុញ្ញាតពីមុន។
3. ការបដិសេធទាំងស្រុង ឬការបដិសេធជាផ្នែកណាមួយទៅលើការទូទាត់ថ្លៃចំណាយសម្រាប់សេវាកម្មមួយ។
4. ការខកខានក្នុងការផ្តល់សេវាកម្មផ្សេងៗឱ្យបានទាន់ពេលវេលា។
5. ការខកខានក្នុងការធ្វើសកម្មភាពក្នុងរយៈពេលដែលតម្រូវចាំបាច់ឱ្យធ្វើ សម្រាប់ដំណោះស្រាយបែបធម្មតាទៅនឹងការប្តឹងអំពីភាពអយុត្តិធម៌ និងការប្តឹងឧទ្ធរណ៍ (ការប្តឹងបន្ត) ទាំងឡាយ (ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត ហើយគម្រោងថែទាំសុខភាពផ្លូវចិត្តមិនឆ្លើយតបមកអ្នកវិញជាមួយនឹងការសម្រេចចិត្តជាលាយលក្ខណ៍អក្សរ ទៅនឹងការប្តឹងរបស់អ្នកក្នុងរយៈពេល 90 ថ្ងៃទេនោះ។ ប្រសិន បើអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត ហើយគម្រោងថែទាំសុខភាពផ្លូវចិត្តមិនឆ្លើយតបមកអ្នកវិញជាមួយនឹងការសម្រេចចិត្តជាលាយលក្ខណ៍អក្សរ ទៅនឹងការប្តឹងឧទ្ធរណ៍របស់អ្នកក្នុងអំឡុងពេល 30 ថ្ងៃ ឬប្រសិនបើអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍បែបឆាប់រហ័ស ហើយមិនបានទទួលការឆ្លើយតបក្នុងរយៈពេល 72 ម៉ោងទេនោះ។)។ ឬក៏
6. ការបដិសេធសំណើរបស់អ្នកទទួលបានអត្ថប្រយោជន៍ ដើម្បីជំទាស់ទៅនឹងការទទួលខុសត្រូវផ្នែកប្រាក់កាស។

## តើសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍គឺជាអ្វី?

សេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) គឺជាលិខិតមួយដែលគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងផ្ញើមកអ្នក ប្រសិនបើពួកគេសម្រេចចិត្តបដិសេធ ឬដាក់កំណត់ ឬកាត់បន្ថយ ឬពន្យារពេល ឬក៏បញ្ចប់សេវាកម្មទាំងឡាយដែលអ្នក និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ជឿជាក់ថាអ្នកគួរតែទទួលបាននោះ។ ចំណុចនេះរួមមានទាំងការបដិសេធចំពោះការបង់ប្រាក់សម្រាប់សេវាកម្មមួយ ឬការបដិសេធដោយផ្អែកទៅលើការទាមទារថាមិនមានការចេញថ្លៃចំណាយចំពោះសេវាកម្មផ្សេងៗ ឬការបដិសេធដោយផ្អែកទៅលើការទាមទារថាសេវាកម្មផ្សេងៗគឺមិនមែនជាការចាំបាច់ទៅតាមផ្នែកពេទ្យទេ ឬការបដិសេធថាសេវាកម្មនេះគឺសម្រាប់ប្រព័ន្ធចែកចាយដែលមិនត្រឹមត្រូវ ឬក៏ការបដិសេធសំណើដើម្បីជំទាស់ទៅនឹងការទទួលខុសត្រូវផ្នែកប្រាក់កាស។ សេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍នេះក៏ប្រើប្រាស់ដើម្បីប្រាប់អ្នកផងដែរថាប្រសិនបើការប្តឹងអំពីភាពអយុត្តិធម៌ ឬការប្តឹងឧទ្ធរណ៍ (ការប្តឹងបន្ត) បែបធម្មតា ឬការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សរបស់អ្នកមិនត្រូវបានដោះស្រាយទាន់ពេលវេលា ឬប្រសិនបើអ្នកមិនបានទទួលសេវាកម្មនៅក្នុងការកំណត់ពេលវេលារបស់គម្រោងថែទាំសុខភាពផ្លូវចិត្តសម្រាប់ការផ្តល់ជូនសេវាកម្មទេនោះ។

## ពេលវេលានៃការផ្តល់សេចក្តីជូនដំណឹង

គម្រោងនេះត្រូវតែផ្ញើសេចក្តីជូនដំណឹងទៅអ្នកទទួលបានអត្ថប្រយោជន៍ក្នុងរយៈពេលយ៉ាងហោចណាស់ 10 ថ្ងៃមុនកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) នៃការបញ្ចប់ ឬការផ្អាក ឬក៏ការកាត់បន្ថយសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលមានការអនុញ្ញាតពីមុន។ គម្រោងនេះក៏ត្រូវតែផ្ញើសេចក្តីជូនដំណឹងទៅកាន់អ្នកទទួលបានអត្ថប្រយោជន៍ក្នុងរយៈពេល ពីរថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) នៃការសម្រេចចិត្តសម្រាប់ការបដិសេធការបង់ប្រាក់ ឬការសម្រេចចិត្តដែលបណ្តាលឱ្យមានការបដិសេធ ឬការពន្យារពេល ឬក៏ការកែប្រែទាំងអស់ ឬជាផ្នែកទៅនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលបានស្នើសុំនេះ។

## តើខ្ញុំនឹងទទួលបានការជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍គ្រប់ពេលវេលាដែលខ្ញុំមិនទទួលបានសេវាកម្មដែលខ្ញុំចង់បាន មែនឬទេ?

មានករណីខ្លះដែលអ្នកអាចនឹងមិនទទួលបានការជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ទេ។ អ្នកនៅតែអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់គម្រោងរបស់ខោនធី (County Plan) បាន ឬប្រសិនបើអ្នកបានបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍ហើយ អ្នកអាចស្នើសុំឡើងសវនាការយុត្តិធម៌របស់រដ្ឋ (state fair hearing) នៅពេលដែលចំណុចទាំងនេះកើតឡើង។ ព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬរបៀបស្នើសុំឡើងសវនាការយុត្តិធម៌គឺមានផ្តល់ជូននៅក្នុងសៀវភៅណែនាំនេះ។ ព័ត៌មាននេះក៏គួរតែមាននៅតាមការិយាល័យអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកផងដែរ។

### តើសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍នេះនឹងប្រាប់អ្វីខ្លះដល់ខ្ញុំ?

សេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍នេះនឹងប្រាប់អ្នកអំពីៈ

- ការសម្រេចចិត្តដែលគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកបានធ្វើឡើង ហើយដែលនឹងប៉ះពាល់ដល់អ្នក និងលទ្ធភាពរបស់អ្នកក្នុងការទទួលបានសេវាកម្មផ្សេងៗ
- កាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ដែលការសម្រេចចិត្តនឹងមានប្រសិទ្ធិភាព និងហេតុផលសម្រាប់ការសម្រេចចិត្ត
- ច្បាប់របស់រដ្ឋ (ស្តេត) ឬច្បាប់របស់រដ្ឋាភិបាល ដែលការសម្រេចចិត្តនោះផ្អែកទៅលើ
- សិទ្ធិទាំងឡាយរបស់អ្នកក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងសេចក្តីសម្រេចរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តទេ
- របៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្ត
- របៀបស្នើសុំឡើងសវនាការថ្នាក់រដ្ឋ (State Hearing) ប្រសិនបើអ្នកមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចរបស់គម្រោងថែទាំសុខភាពផ្លូវចិត្ត លើបណ្តឹងឧទ្ធរណ៍របស់អ្នកទេនោះ។
- របៀបស្នើសុំបណ្តឹងឧទ្ធរណ៍បែបឆាប់រហ័ស ឬការឡើងសវនាការថ្នាក់រដ្ឋបែបឆាប់រហ័ស
- របៀបទទួលបានជំនួយក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬជំនួយក្នុងការស្នើសុំឡើងសវនាការថ្នាក់រដ្ឋ
- រយៈពេលដែលអ្នកមានក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬការស្នើសុំឡើងសវនាការថ្នាក់រដ្ឋ
- សិទ្ធិរបស់អ្នកក្នុងការបន្តទទួលបានសេវាកម្ម ខណៈពេលដែលអ្នករង់ចាំសេចក្តីសម្រេចនៃការប្តឹងឧទ្ធរណ៍ ឬការឡើងសវនាការថ្នាក់រដ្ឋ និងរបៀបស្នើសុំសេវាកម្មទាំងនេះបន្ត ហើយនិងថាតើការចំណាយទៅលើសេវាកម្មទាំងនេះនឹងត្រូវចេញថ្លៃជូនដោយកម្មវិធីធានារ៉ាប់រង Medi-Cal ឬទេ
- ពេលដែលអ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក ឬស្នើសុំឡើងសវនាការថ្នាក់រដ្ឋ ប្រសិនបើអ្នកចង់ឱ្យសេវាកម្មទាំងឡាយនៅបន្ត។

### តើខ្ញុំគួរតែធ្វើយ៉ាងដូចម្តេច នៅពេលដែលខ្ញុំទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍នោះ?

នៅពេលដែលអ្នកទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) អ្នកគួរតែអានព័ត៌មានទាំងអស់នៅលើសេចក្តីជូនដំណឹងនោះដោយប្រុងប្រយ័ត្ន។ ប្រសិនបើអ្នកមិនយល់អំពីសេចក្តីជូនដំណឹងនោះទេ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកអាចជួយអ្នកបាន។ អ្នកក៏អាចស្នើសុំឱ្យមនុស្សផ្សេងម្នាក់ទៀតជួយអ្នកបានផងដែរ។

ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តប្រាប់អ្នកថាសេវាកម្មរបស់អ្នកនឹងបញ្ចប់ ឬមានការកាត់បន្ថយ ហើយអ្នកមិនយល់ស្របទៅនឹងការសម្រេចចិត្តនេះទេ អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងឧទ្ធរណ៍ (បណ្តឹងបន្ត) ចំពោះការសម្រេចចិត្តនេះ។ អ្នកអាចបន្តទទួលបានសេវាកម្មផ្សេងៗរហូតដល់ការប្តឹងឧទ្ធរណ៍ ឬការឡើងសវនាការថ្នាក់រដ្ឋ (State Hearing) របស់អ្នកត្រូវបានកាត់សេចក្តី។

អ្នកត្រូវតែស្នើសុំការបន្តសេវាកម្មមិនឱ្យលើសពី 10 ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ ឬមុនកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) នៃការផ្លាស់ប្តូរចាប់ផ្តើមមានប្រសិទ្ធិភាពនោះ។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ដំណើរការនៃការដោះស្រាយបញ្ហា៖ ការដាក់ពាក្យបណ្ដឹងអំពីភាពអយុត្តិធម៌ ឬការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍

### ចុះប្រសិនបើខ្ញុំមិនទទួលបានសេវាកម្មទាំងឡាយដែលខ្ញុំចង់បានពីគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់ខ្ញុំទេនោះ?

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកត្រូវតែមានដំណើរការសម្រាប់ឱ្យអ្នកដោះស្រាយការមិនពេញចិត្ត ឬបញ្ហាអំពីការមិនយល់ព្រមណាមួយដែលទាក់ទងទៅនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលអ្នកចង់បាន ឬកំពុងទទួលបាន។ ចំណុចនេះគឺហៅថា ដំណើរការនៃដោះស្រាយបញ្ហា ហើយអាចពាក់ព័ន្ធទៅនឹង៖

1. **ដំណើរការនៃការប្ដឹងអំពីភាពអយុត្តិធម៌ (The Grievance Process)**៖ ការបង្ហាញពីការមិនសប្បាយចិត្តអំពីអ្វីក៏ដោយដែលទាក់ទងទៅនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស ឬក៏គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក។
2. **ដំណើរការនៃការប្ដឹងឧទ្ធរណ៍ (ការប្ដឹងបន្ត) (The Appeal Process)**៖ ការពិនិត្យឡើងវិញចំពោះការសម្រេចចិត្ត (ឧ. ដូចជា ការបដិសេធ ឬការបញ្ចប់ ឬក៏ការកាត់បន្ថយសេវាកម្មផ្សេងៗ) ដែលបានធ្វើឡើងអំពីសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់អ្នកដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត ឬអ្នកផ្ដល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។
3. **ដំណើរការនៃការឡើងសវនាការថ្នាក់រដ្ឋ (The State Hearing Process)**៖ ដំណើរការស្នើសុំឡើងសវនាការថ្នាក់រដ្ឋបាលនៅចំពោះមុខចៅក្រមផ្នែកច្បាប់រដ្ឋបាលរបស់រដ្ឋ (ស្តេត) ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តបដិសេធបណ្ដឹងឧទ្ធរណ៍របស់អ្នក។

ការដាក់ពាក្យបណ្ដឹងអំពីភាពអយុត្តិធម៌ ឬការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ឬក៏ការស្នើសុំឡើងសវនាការថ្នាក់រដ្ឋនឹងមិនត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នកទេ ហើយនឹងមិនប៉ះពាល់ដល់សេវាកម្មទាំងឡាយដែលអ្នកកំពុងទទួលបានឡើយ។ ការដាក់ពាក្យបណ្ដឹងអំពីភាពអយុត្តិធម៌ ឬការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ជួយឱ្យអ្នកទទួលបានសេវាកម្មទាំងឡាយដែលអ្នកត្រូវការ និងដោះស្រាយបញ្ហាណាមួយដែលអ្នកមានជាមួយនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់អ្នក។ ការប្ដឹងអំពីភាពអយុត្តិធម៌ និងការប្ដឹងឧទ្ធរណ៍ក៏ជួយទៅគម្រោងថែទាំសុខភាពផ្លូវចិត្តផងដែរ ដោយផ្ដល់ឱ្យពួកគេនូវព័ត៌មានដែលពួកគេអាចប្រើប្រាស់ដើម្បីកែលម្អសេវាកម្មទាំងឡាយបាន។ នៅពេលដែលការប្ដឹងអំពីភាពអយុត្តិធម៌ ឬការប្ដឹងឧទ្ធរណ៍របស់អ្នកបានបញ្ចប់នោះ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជូនដំណឹងដល់អ្នក និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធ អំពីលទ្ធផលចុងក្រោយ។ នៅពេលការឡើងសវនាការថ្នាក់រដ្ឋរបស់អ្នកត្រូវបានកាត់សេចក្ដីរួច ការិយាល័យសវនាការថ្នាក់រដ្ឋ (State Hearing Office) នឹងជូនដំណឹងដល់អ្នក និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធ អំពីលទ្ធផលចុងក្រោយ។ អ្នកអាចស្វែងយល់បន្ថែមអំពីដំណើរការនៃការដោះស្រាយបញ្ហានីមួយៗ នៅខាងក្រោមនេះ។

### តើខ្ញុំអាចទទួលបានជំនួយក្នុងការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ឬដាក់ពាក្យបណ្ដឹងអំពីភាពអយុត្តិធម៌ ឬក៏ការឡើងសវនាការថ្នាក់រដ្ឋបាន ដែរឬទេ?

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជួយពន្យល់អំពីដំណើរការទាំងនេះដល់អ្នកបាន ហើយត្រូវតែជួយអ្នកក្នុងការដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ ឬពាក្យបណ្តឹងឧទ្ធរណ៍ ឬក៏ស្នើសុំឡើងសវនាការថ្នាក់រដ្ឋ (State Hearing)។
គម្រោងថែទាំសុខភាពផ្លូវចិត្តក៏អាចជួយអ្នកក្នុងការសម្រេចចិត្តថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ចំណុចមួយហៅថាដំណើរការ "បណ្តឹងឧទ្ធរណ៍បែបឆាប់រហ័ស" ដែលមានន័យថាបណ្តឹងនេះនឹងត្រូវបានពិនិត្យឡើងវិញកាន់តែលឿន ដោយសារតែសុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត និង/ឬស្ថេរភាពរបស់អ្នកគឺប្រឈមនឹងហានិភ័យ។
អ្នកក៏អាចនឹងផ្តល់ការអនុញ្ញាតឱ្យបុគ្គលម្នាក់ផ្សេងទៀតក្នុងការធ្វើសកម្មភាពជំនួសអ្នក រួមទាំងអ្នកផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់អ្នក ឬអ្នកគាំទ្រមតិ (advocate) ម្នាក់បានផងដែរ។
ប្រសិនបើអ្នកចង់បានជំនួយ សូមទូរស័ព្ទទៅកាន់លេខ *[County to Insert Toll-Free Phone Number]។
គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកត្រូវតែផ្តល់ជូនអ្នកនូវជំនួយដោយសមហេតុផលមួយចំពោះការបំពេញបែបបទ និងជំហានផ្សេងទៀតក្នុងដំណើរការដែលទាក់ទងទៅនឹងការប្តឹងអំពីភាពអយុត្តិធម៌ ឬការប្តឹងឧទ្ធរណ៍នេះ។
ជំនួយប្រភេទនេះរួមមានដូចជា ការផ្តល់សេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ និងលេខទូរស័ព្ទមិនគិតថ្លៃដែលមានសម្រាប់អ្នកថ្លង់  (TTY/TDD) និងអាចបកប្រែផ្ទាល់មាត់បាន ប៉ុន្តែមិនមែនមានត្រឹមតែចំណុចទាំងនេះនោះទេ។

**តើរដ្ឋ (ស្តេត) អាចជួយខ្ញុំជាមួយនឹងបញ្ហា/សំណួររបស់ខ្ញុំបាន ដែរឬទេ?**

អ្នកអាចនឹងទាក់ទងទៅកាន់ការិយាល័យមន្ត្រីស៊ើបអង្កេតនិងទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ របស់នាយកដ្ឋានសេវាកម្មផ្នែកថែទាំសុខភាព (Department of Health Care Services, Office of the Ombudsman) ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច (មិនគិតថ្ងៃឈប់សម្រាក) ដោយទូរស័ព្ទ តាមរយៈលេខ **888-452-8609** ឬដោយអ៊ីម៉ែល តាមរយៈ MMCDOmbudsmanOffice@dhcs.ca.gov។ **សូមកត់សម្គាល់៖** សារតាមរយៈអ៊ីម៉ែលមិនត្រូវបានចាត់ទុកថាជាការសម្ងាត់នោះទេ។ អ្នកមិនគួរបញ្ចូលព័ត៌មានផ្ទាល់ខ្លួនទៅក្នុងសារតាមរយៈអ៊ីម៉ែលឡើយ។

អ្នកក៏អាចនឹងទទួលបានជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃនៅតាមការិយាល័យជំនួយផ្នែកច្បាប់ក្នុងតំបន់របស់អ្នក ឬក្រុមផ្សេងទៀត។ អ្នកក៏អាចទាក់ទងទៅកាន់នាយកដ្ឋានសេវាកម្មសង្គមនៃរដ្ឋ California (California Department of Social Services/CDSS) ដើម្បីសាកសួរអំពីសិទ្ធិឡើងសវនាការរបស់អ្នក ដោយទាក់ទងទៅកាន់ អង្គភាពស៊ើបអង្កេតនិងឆ្លើយតបសាធារណៈ (Public Inquiry and Response Unit) របស់ពួកគេដោយទូរស័ព្ទតាមរយៈលេខ **800-952-5253** (សម្រាប់អ្នកថ្លង់ (TTY) សូមទូរស័ព្ទទៅកាន់លេខ **800-952-8349**)។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ដំណើរការនៃការប្តឹងអំពីភាពអយុត្តិធម៌

### តើការប្តឹងអំពីភាពអយុត្តិធម៌គឺជាអ្វី?

ការប្តឹងអំពីភាពអយុត្តិធម៌ (grievance) គឺជាការបង្ហាញអំពីការមិនពេញចិត្តចំពោះអ្វីទាំងអស់ដែលទាក់ទងទៅនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់អ្នក ហើយមិនមែនជាបញ្ហាមួយដែលដោះស្រាយដោយដំណើរការនៃការប្តឹងឧទ្ធរណ៍ (appeal) និងការឡើងសវនាការថ្នាក់រដ្ឋ (State Hearing) នោះឡើយ។

### តើដំណើរការនៃការប្តឹងអំពីភាពអយុត្តិធម៌គឺជាអ្វី?

ដំណើរការនៃការប្តឹងអំពីភាពអយុត្តិធម៌គឺជាដំណើរការរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តសម្រាប់ការពិនិត្យឡើងវិញនូវបណ្តឹងអំពីភាពអយុត្តិធម៌ ឬបណ្តឹងអំពីការមិនពេញចិត្តរបស់អ្នកទាក់ទងទៅនឹងសេវាកម្មទាំងឡាយរបស់អ្នក ឬគម្រោងថែទាំសុខភាពផ្លូវចិត្តនេះ។ ការប្តឹងអំពីភាពអយុត្តិធម៌អាចធ្វើឡើងនៅពេលណាក៏បាន ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយការប្តឹងអំពីភាពអយុត្តិធម៌នេះនឹងមិនធ្វើឱ្យអ្នកបាត់បង់សិទ្ធិ ឬសេវាកម្មផ្សេងៗរបស់អ្នកទេ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកនឹងមិនមានបញ្ហាអ្វីនោះដែរ។

អ្នកអាចផ្តល់សិទ្ធិឱ្យអ្នកផ្សេងម្នាក់ទៀត ឬហៅថាអ្នកគាំទ្រមតិ (advocate) ឬក៏អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ដើម្បីធ្វើសកម្មភាពជំនួសអ្នក។ ប្រសិនបើអ្នកអនុញ្ញាតឱ្យមនុស្សម្នាក់ផ្សេងទៀតធ្វើសកម្មភាពតំណាងឱ្យអ្នកនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តអាចនឹងស្នើសុំឱ្យអ្នកចុះហត្ថលេខានៅលើបែបបទមួយដែលអនុញ្ញាតឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្តបង្ហាញព័ត៌មានទៅកាន់បុគ្គលម្នាក់នោះ។

បុគ្គលណាម្នាក់ដែលធ្វើការឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្ត ហើយដែលសម្រេចលើបណ្តឹងអំពីភាពអយុត្តិធម៌នេះ ត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចចិត្ត និងមិនពាក់ព័ន្ធទៅនឹងការពិនិត្យឡើងវិញ ឬការសម្រេចចិត្តពីកម្រិតមុនណាមួយឡើយ។

### តើខ្ញុំអាចដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌បាននៅពេលណា?

អ្នកអាចដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌បាននៅពេលណាក៏បានទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិនបើអ្នកមិនសប្បាយចិត្តនឹងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសផ្សេងៗ ឬមានកង្វល់មួយផ្សេងទៀតទាក់ទងទៅនឹងគម្រោងថែទាំសុខភាពផ្លូវចិត្តនោះ។

### តើខ្ញុំអាចដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌បានដោយរបៀបណា?

អ្នកអាចនឹងទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក *[County to Insert Toll-Free Phone Number If Different Than the Footer] ដើម្បីទទួលបានជំនួយជាមួយនឹងការប្តឹងអំពីភាពអយុត្តិធម៌។

បណ្តឹងអំពីភាពអយុត្តិធម៌អាចធ្វើឡើងបានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ បណ្តឹងអំពីភាពអយុត្តិធម៌ផ្ទាល់មាត់មិនចាំបាច់ត្រូវមានការដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរតាមក្រោយទេ។ ប្រសិនបើអ្នកចង់ដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នកជាលាយលក្ខណ៍អក្សរនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងផ្តល់ជូននូវស្រោមសំបុត្រដែលមានអាស័យដ្ឋានស្រាប់ នៅតាមទីតាំងទាំងអស់របស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ដើម្បីឱ្យអ្នកផ្ញើសំបុត្រនៃបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នកបាន។ ប្រសិនបើអ្នកមិនមានស្រោមសំបុត្រដែលអាស័យដ្ឋានស្រាប់ទេនោះ អ្នកអាចផ្ញើបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នកដោយផ្ទាល់ទៅកាន់អាស័យដ្ឋានដែលមានផ្តល់ជូននៅផ្នែកខាងមុខនៃសៀវភៅណែនាំនេះ។

**តើខ្ញុំនឹងបានដោយរបៀបណា ថាតើគម្រោងថែទាំសុខភាពផ្លូវចិត្តបានទទួលបណ្តឹងអំពីភាពអយុត្តិធម៌របស់ខ្ញុំ ឬអត់នោះ?**

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតម្រូវចាំបាច់ត្រូវជូនដំណឹងដល់អ្នកថាពួកគេបានទទួលបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នក ដោយការផ្ញើលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរមកអ្នកវិញ។

**តើបណ្តឹងអំពីភាពអយុត្តិធម៌របស់ខ្ញុំនឹងត្រូវសម្រេចនៅពេលណា?**

គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែធ្វើការសម្រេចចិត្តអំពីការប្តឹងអំពីភាពអយុត្តិធម៌របស់អ្នកក្នុងអំឡុងពេល 90 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ចាប់តាំងពីថ្ងៃដែលអ្នកបានដាក់ពាក្យបណ្តឹងរបស់អ្នករួច។ ពេលវេលាកំណត់សម្រាប់ធ្វើការសម្រេចចិត្តនេះអាចពន្យាររហូតដល់ 14 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ប្រសិនបើអ្នកស្នើសុំការបន្ថែមពេលវេលានេះ ឬប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តជឿជាក់ថាមានតម្រូវការសម្រាប់ការទទួលព័ត៌មានបន្ថែម ហើយការពន្យារពេលនេះគឺសម្រាប់ជាផលប្រយោជន៍ដល់អ្នក។ ឧទាហរណ៍នៃករណីដែលការពន្យារពេលអាចក្លាយទៅជាផលប្រយោជន៍ដល់អ្នកនោះ គឺនៅពេលដែលគម្រោងថែទាំសុខភាពផ្លូវចិត្តជឿជាក់ថាពួកគេអាចដោះស្រាយបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នកបាន ប្រសិនបើពួកគេមានពេលវេលាច្រើនជាងនេះក្នុងការទទួលបានព័ត៌មានពីអ្នក ឬអ្នកផ្សេងទៀតដែលពាក់ព័ន្ធ។

**តើខ្ញុំនឹងបានដោយរបៀបណា ថាតើគម្រោងថែទាំសុខភាពផ្លូវចិត្តបានធ្វើការសម្រេចចិត្តអំពីបណ្តឹងអំពីភាពអយុត្តិធម៌របស់ខ្ញុំនោះ?**

នៅពេលដែលមានការសម្រេចចិត្តទាក់ទងទៅនឹងបណ្តឹងអំពីភាពអយុត្តិធម៌របស់អ្នកហើយនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងជូនដំណឹងដល់អ្នក ឬតំណាងរបស់អ្នកជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តនេះ។ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកមិនបានជូនដំណឹងដល់អ្នក ឬភាគីដែលរងផលប៉ះពាល់ណាមួយអំពីការសម្រេចចិត្តនៃការប្តឹងអំពីភាពអយុត្តិធម៌ទាន់ពេលវេលាទេនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) ដែលណែនាំអ្នកអំពីសិទ្ធិរបស់អ្នកក្នុងការស្នើសុំឡើងសវនាការថ្នាក់រដ្ឋ (State

Hearing)។
មានការតម្រូវចាំបាច់ឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ នៅនឹងកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ដែលពេលវេលាកំណត់នោះបានហួសផុតទៅ។ អ្នកអាចនឹងទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តសម្រាប់ព័ត៌មានបន្ថែម ប្រសិនបើអ្នកមិនបានទទួលសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ទេនោះ។

**តើមានកាលកំណត់សម្រាប់ដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ ដែរឬទេ?**

ទេ! អ្នកអាចដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌បានគ្រប់ពេល។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## ដំណើរការនៃការប្តឹងឧទ្ធរណ៍ (បែបធម្មតា និងបែបឆាប់រហ័ស)

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកត្រូវតែអនុញ្ញាតឱ្យអ្នកជំទាស់ទៅនឹងការសម្រេចចិត្តដោយគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ដែលអ្នកមិនយល់ស្របជាមួយ និងស្នើសុំឱ្យពិនិត្យឡើងវិញនូវការសម្រេចចិត្តជាក់លាក់មួយចំនួនដែលធ្វើឡើងដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអំពីសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់អ្នក។ អ្នកអាចស្នើសុំការត្រួតពិនិត្យឡើងវិញតាមវិធីចំនួនពីរ។ វិធីទីមួយគឺប្រើប្រាស់ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបធម្មតា (standard appeal)។ វិធីផ្សេងមួយទៀតគឺដោយប្រើប្រាស់ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបឆាប់រហ័ស (expedited appeal)។ ប្រភេទបណ្តឹងឧទ្ធរណ៍ទាំងពីរនេះគឺប្រហាក់ប្រហែលនឹងគ្នា ប៉ុន្តែមានតម្រូវការជាក់លាក់មួយចំនួនដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សនោះ។ តម្រូវការជាក់លាក់ទាំងឡាយនឹងត្រូវពន្យល់ដូចខាងក្រោមនេះ។

### តើបណ្តឹងឧទ្ធរណ៍បែបធម្មតាគឺជាអ្វី?

បណ្តឹងឧទ្ធរណ៍បែបធម្មតា (standard appeal) គឺជាការស្នើសុំឱ្យពិនិត្យឡើងវិញនូវការសម្រេចចិត្តមួយដែលបានធ្វើឡើងដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ដែលពាក់ព័ន្ធទៅនឹងការបដិសេធ ឬការផ្លាស់ប្តូរចំពោះសេវាកម្មផ្សេងៗដែលអ្នកគិតថាអ្នកត្រូវការ។ ប្រសិនបើអ្នកស្នើសុំការប្តឹងឧទ្ធរណ៍បែបធម្មតានោះ គម្រោងថែទាំសុខភាពផ្លូវចិត្តអាចនឹងចំណាយពេលរហូតដល់ 30 ថ្ងៃដើម្បីពិនិត្យមើលបណ្តឹងនេះ។ ប្រសិនបើអ្នកគិតថាការរង់ចាំរយៈពេល 30 ថ្ងៃនឹងធ្វើឱ្យសុខភាពរបស់អ្នកប្រឈមនឹងហានិភ័យ អ្នកគួរតែស្នើសុំ “ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័ស (expedited appeal)”។ ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបធម្មតានឹង៖

- អនុញ្ញាតឱ្យអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។
- ធានាថាការដាក់ពាក្យបណ្តឹងឧទ្ធរណ៍នឹងមិនត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹងអ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ក្នុងលក្ខណៈណាមួយឡើយ។
- អនុញ្ញាតឱ្យអ្នកផ្តល់សិទ្ធិដល់បុគ្គលម្នាក់ផ្សេងទៀតក្នុងការធ្វើសកម្មភាពជំនួសអ្នក រួមទាំងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ផងដែរ។ ប្រសិនបើអ្នកអនុញ្ញាតឱ្យមនុស្សម្នាក់ផ្សេងទៀតធ្វើសកម្មភាពជំនួសអ្នកនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តប្រហែលជាអាចស្នើសុំឱ្យអ្នកចុះហត្ថលេខានៅលើបែបបទមួយដែលអនុញ្ញាតឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្តបង្ហាញព័ត៌មានទៅកាន់បុគ្គលម្នាក់នោះ។
- បន្តផ្តល់អត្ថប្រយោជន៍ដល់អ្នក នៅពេលមានការស្នើសុំការប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលវេលាដែលបានកំណត់ នោះគឺរយៈពេល 10 ថ្ងៃចាប់តាំងពីកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) នៃការផ្ញើសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) របស់អ្នកតាមសំបុត្រ ឬប្រគល់ឱ្យអ្នកដោយផ្ទាល់នោះ។ អ្នកមិនចាំបាច់បង់ប្រាក់សម្រាប់សេវាកម្មបន្តទេ ខណៈពេលដែលកំពុងរង់ចាំលទ្ធផលបណ្តឹងឧទ្ធរណ៍នោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកស្នើសុំការបន្តផ្តល់អត្ថប្រយោជន៍

ហើយការសម្រេចចិត្តចុងក្រោយអំពីការប្តឹងឧទ្ធរណ៍បញ្ជាក់ទៅលើការសម្រេចចិត្តក្នុងការកាត់បន្ថយ ឬបញ្ឈប់សេវាកម្មដែលអ្នកកំពុងទទួលបានមែននោះ អ្នកអាចនឹងតម្រូវចាំបាច់ត្រូវបង់ថ្លៃសេវាកម្មដែលបានផ្តល់ជូន ខណៈពេលកំពុងរង់ចាំបណ្តឹងឧទ្ធរណ៍នោះ។

- ធានាថាបុគ្គលទាំងឡាយដែលធ្វើការសម្រេចចិត្តលើបណ្តឹងឧទ្ធរណ៍របស់អ្នក មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើដូច្នេះ និងមិនពាក់ព័ន្ធទៅនឹងការពិនិត្យឡើងវិញ ឬការសម្រេចចិត្តពីកម្រិតមុនណាមួយឡើយ។
- អនុញ្ញាតឱ្យអ្នក ឬតំណាងរបស់អ្នកពិនិត្យមើលឯកសារករណីរបស់អ្នក រួមទាំងកំណត់ត្រាផ្នែកសុខភាពរបស់អ្នក ហើយនិងឯកសារឬកំណត់ត្រាផ្សេងទៀតដែលមានការពិចារណាថាអាចទាក់ទង ក្នុងអំឡុងពេលដំណើរការបណ្តឹងឧទ្ធរណ៍នេះ។
- អនុញ្ញាតឱ្យអ្នកមានឱកាសដោយសមហេតុផលក្នុងការបង្ហាញភ័ស្តុតាង និងចម្លើយរបស់សាក្សី ហើយធ្វើការតវ៉ាតាមផ្លូវច្បាប់ និងជាការពិត ដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរ។
- អនុញ្ញាតឱ្យអ្នក ឬតំណាងរបស់អ្នក ឬក៏អ្នកតំណាងស្របច្បាប់របស់កេរមរតក (estate) របស់អ្នកទទួលបានអត្ថប្រយោជន៍ដែលបានស្លាប់ថា ត្រូវតែដាក់បញ្ចូលជាភាគីនៃបណ្តឹងឧទ្ធរណ៍នោះ។
- ប្រាប់អ្នកឱ្យដឹងថាបណ្តឹងឧទ្ធរណ៍របស់អ្នកកំពុងត្រូវបានពិនិត្យឡើងវិញ ដោយផ្ញើលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរមួយទៅអ្នក។
- ជូនដំណឹងដល់អ្នកអំពីសិទ្ធិរបស់អ្នកក្នុងការស្នើសុំឡើងសវនាការថ្នាក់រដ្ឋ (State Hearing) បន្ទាប់ពីការបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍ជាមួយនឹងគម្រោងថែទាំសុខភាពផ្លូវចិត្តរួច។

**តើខ្ញុំអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាននៅពេលណា?**

អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក នៅក្នុងស្ថានភាពទាំងឡាយខាងក្រោមនេះ៖

- គម្រោងថែទាំសុខភាពផ្លូវចិត្ត ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលជាប់កិច្ចសន្យាម្នាក់ សម្រេចថាអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសរបស់កម្មវិធីធានារ៉ាប់រង Medi-Cal ពីព្រោះអ្នកមិនស្របតាមល័ក្ខខ័ណ្ឌនៃការចាំបាច់ទៅតាមផ្នែកពេទ្យ (medical necessity) ទេនោះ។
- អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកគិតថាអ្នកត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស ហើយស្នើសុំការអនុញ្ញាតពីគម្រោងថែទាំសុខភាពផ្លូវចិត្ត ប៉ុន្តែគម្រោងថែទាំសុខភាពផ្លូវចិត្តមិនយល់ព្រម ហើយបដិសេធសំណើរបស់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនោះ ឬក៏ផ្លាស់ប្តូរប្រភេទ ឬភាពញឹកញាប់នៃការទទួលបានសេវាកម្មនោះ។
- អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកបានស្នើសុំការអនុញ្ញាតពីគម្រោងថែទាំសុខភាពផ្លូវចិត្ត ប៉ុន្តែគម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវការព័ត៌មានបន្ថែមដើម្បីធ្វើការសម្រេចចិត្ត ហើយមិនបានបញ្ចប់ដំណើរការនៃការអនុញ្ញាតបានទាន់ពេលវេលាទេនោះ។
- គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកមិនផ្តល់សេវាកម្មផ្សេងៗដល់អ្នកដោយផ្អែកទៅលើពេលវេលាដែល

គម្រោងថែទាំសុខភាពផ្លូវចិត្តបានកំណត់នោះទេ។

- អ្នកមិនគិតថាគម្រោងថែទាំសុខភាពផ្លូវចិត្តកំពុងផ្តល់សេវាកម្មផ្សេងៗបានទាន់ពេលវេលាទៅតាមតម្រូវការរបស់អ្នកទេនោះ។
- ការប្តឹងអំពីភាពអយុត្តិធម៌ ឬការប្តឹងឧទ្ធរណ៍ ឬក៏ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សរបស់អ្នកមិនត្រូវបានដោះស្រាយទាន់ពេលវេលាទេនោះ។
- អ្នក និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកមិនយល់ព្រមទៅលើសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលអ្នកត្រូវការទេនោះ។

**តើខ្ញុំអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានដោយរបៀបណា?**

អ្នកអាចទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក *[mental health plan to Insert Toll-Free Phone Number if Different Than the Footer] ដើម្បីទទួលបានជំនួយក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងផ្តល់ស្រោមសំបុត្រដែលមានអាសយដ្ឋានស្រាប់នៅគ្រប់ទីតាំងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ដើម្បីឱ្យអ្នកផ្ញើបណ្តឹងឧទ្ធរណ៍របស់អ្នក។ ប្រសិនបើអ្នកមិនមានស្រោមសំបុត្រដែលមានអាស័យដ្ឋានស្រាប់ទេនោះ អ្នកអាចផ្ញើបណ្តឹងឧទ្ធរណ៍របស់អ្នកដោយផ្ទាល់ទៅកាន់អាស័យដ្ឋាននៅផ្នែកខាងមុខនៃសៀវភៅណែនាំនេះ ឬអ្នកអាចដាក់បញ្ជូនបណ្តឹងឧទ្ធរណ៍របស់អ្នកតាមអ៊ីម៉ែល ឬទូរសារ (ហ្វេក) ទៅកាន់ *[mental health plan To Insert E-Mail Address and Fax Number for Appeals]។

**តើខ្ញុំដឹងបានដោយរបៀបណា ថាតើបណ្តឹងឧទ្ធរណ៍របស់ខ្ញុំត្រូវបានសម្រេចនោះ?**

គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងជូនដំណឹងដល់អ្នក ឬតំណាងរបស់អ្នកជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តរបស់ពួកគេសម្រាប់ការប្តឹងឧទ្ធរណ៍របស់អ្នក។ សេចក្តីជូនដំណឹងនោះនឹងមានព័ត៌មានដូចខាងក្រោម៖

- លទ្ធផលដំណើរការនៃការដោះស្រាយបណ្តឹងឧទ្ធរណ៍។
- កាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ដែលការសម្រេចចិត្តអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើង។
- ប្រសិនបើបណ្តឹងឧទ្ធរណ៍មិនត្រូវបានដោះស្រាយដោយសម្រេចគាំទ្រអ្នកទាំងស្រុងនោះទេ សេចក្តីជូនដំណឹងនេះក៏នឹងមានព័ត៌មានទាក់ទងទៅនឹងសិទ្ធិរបស់អ្នកចំពោះការឡើងសវនាការថ្នាក់រដ្ឋ (State Hearing) និងដំណើរការសម្រាប់ការដាក់ពាក្យឡើងសវនាការថ្នាក់រដ្ឋផងដែរ។

**តើមានកាលកំណត់សម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ដែរឬទេ?**

អ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេល 60 ថ្ងៃគិតចាប់តាំងពីកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) នៅក្នុងសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) នោះ។ មិនមានកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះទេ

នៅពេលដែលអ្នកមិនទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ ដូច្នេះអ្នកអាចដាក់បណ្តឹងឧទ្ធរណ៍ប្រភេទនេះនៅពេលណាក៏បាន។

**តើការសម្រេចចិត្តអំពីការប្តឹងឧទ្ធរណ៍របស់ខ្ញុំនឹងត្រូវធ្វើឡើងនៅពេលណា?**

គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងសម្រេចលើការប្តឹងឧទ្ធរណ៍របស់អ្នកក្នុងអំឡុងពេល 30 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ចាប់តាំងពីពេលដែលគម្រោងថែទាំសុខភាពផ្លូវចិត្តបានទទួលសំណើរបស់អ្នកសម្រាប់ការប្តឹងឧទ្ធរណ៍នេះ។ ពេលវេលាកំណាត់សម្រាប់ធ្វើការសម្រេចចិត្តអាចពន្យាររហូតដល់ 14 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ប្រសិនបើអ្នកស្នើសុំការបន្ថែមពេលវេលានេះ ឬប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្ត ជឿជាក់ថាមានតម្រូវការសម្រាប់ការទទួលព័ត៍មានបន្ថែម ហើយការពន្យារពេលនេះគឺសម្រាប់ជាផលប្រយោជន៍ដល់អ្នក។ ឧទាហរណ៍នៃករណីដែលការពន្យារពេលគឺជាផលប្រយោជន៍ដល់អ្នកនោះគឺនៅពេលដែលគម្រោងថែទាំសុខភាពផ្លូវចិត្ត ជឿជាក់ថាពួកគេអាចនឹងអាចដោះស្រាយបណ្តឹងឧទ្ធរណ៍របស់អ្នកបាន ប្រសិនបើពួកគេមានពេលច្រើនជាងនេះក្នុងការទទួលបានព័ត៍មានពីអ្នក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។

**ចុះប្រសិនបើខ្ញុំមិនអាចរង់ចាំការសម្រេចចិត្តអំពីបណ្តឹងឧទ្ធរណ៍របស់ខ្ញុំរហូតដល់ 30 ថ្ងៃទេនោះ?**

ដំណើរការនៃការប្តឹងឧទ្ធរណ៍អាចលឿនជាងនេះ ប្រសិនបើការប្តឹងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបឆាប់រហ័ស។

**តើការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សគឺជាអ្វី?**

ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័ស (expedited appeal) គឺជាវិធីដែលលឿនជាងមុនក្នុងការសម្រេចលើការប្តឹងឧទ្ធរណ៍។ ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សនេះអនុវត្តក្នុងលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងដំណើរការនៃការប្តឹងឧទ្ធរណ៍បែបធម្មតាផងដែរ។ ប៉ុន្តែ អ្នកត្រូវតែបង្ហាញថាការរង់ចាំការប្តឹងឧទ្ធរណ៍បែបធម្មតាអាចធ្វើឱ្យស្ថានភាពសុខភាពផ្លូវចិត្តរបស់អ្នកកាន់តែធ្ងន់ធ្ងរឡើង។ ដំណើរការនៃការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សក៏អនុវត្តតាមកាលកំណត់ខុសគ្នាពីការប្តឹងឧទ្ធរណ៍បែបធម្មតាផងដែរ។ គម្រោងថែទាំសុខភាពផ្លូវចិត្តមានរយៈពេល 72 ម៉ោងដើម្បីពិនិត្យមើលការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សនោះ។ អ្នកអាចធ្វើការស្នើសុំដោយផ្ទាល់មាត់សម្រាប់ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សបាន។ អ្នកមិនចាំបាច់ដាក់សំណើការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សរបស់អ្នកជាលាយលក្ខណ៍អក្សរទេ។

**តើខ្ញុំអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បែបឆាប់រហ័សបាននៅពេលណា?**

ប្រសិនបើអ្នកគិតថាការរង់ចាំរហូតដល់រយៈពេល 30 ថ្ងៃសម្រាប់ការសម្រេចចិត្តលើការប្តឹងឧទ្ធរណ៍បែបធម្មតានឹងធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត សុខភាព ឬសមត្ថភាពក្នុងការទទួលបាន ការរក្សា ឬការទទួលបានមកវិញនូវដំណើរការក្នុងការរស់នៅដែលខ្ពស់បំផុតនោះ អ្នកអាចនឹងស្នើសុំដំណោះស្រាយបែបឆាប់រហ័សមួយសម្រាប់ការប្តឹងឧទ្ធរណ៍។ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តយល់ព្រមថាការប្តឹងឧទ្ធរណ៍របស់អ្នកស្របតាមតម្រូវការទាំងឡាយសម្រាប់ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនឹងដោះស្រាយបណ្តឹងឧទ្ធរណ៍បែបឆាប់រហ័សរបស់អ្នកក្នុងអំឡុងពេល 72 ម៉ោងបន្ទាប់ពីគម្រោងថែទាំសុខភាពផ្លូវចិត្តទទួលបានបណ្តឹងឧទ្ធរណ៍នេះ។ ពេលវេលាកំណត់សម្រាប់ធ្វើការសម្រេចចិត្តអាចនឹងពន្យាររហូតដល់ 14 ថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ប្រសិនបើអ្នកស្នើសុំការបន្ថែមពេលវេលា ឬប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តបង្ហាញថាមានតម្រូវការសម្រាប់ការទទួលព័ត៌មានបន្ថែម ហើយការពន្យារពេលនេះគឺសម្រាប់ជាផលប្រយោជន៍ដល់អ្នក។

ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកបន្ថែមពេលវេលាកំណត់នោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងផ្តល់ជូនអ្នកនូវសេចក្តីពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុដែលមានការបន្ថែមពេលវេលានេះ។ ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តសម្រេចថាការប្តឹងឧទ្ធរណ៍របស់អ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សទេនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែខិតខំប្រឹងប្រែងក្នុងលក្ខណៈសមរម្យមួយដើម្បីផ្តល់ជាដំណឹងដោយផ្ទាល់មាត់ដល់អ្នកភ្លាមៗ ហើយនឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេលពីរថ្ងៃរាប់ក្នុងប្រតិទិន (គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ដែលនឹងប្រាប់អ្នកអំពីហេតុផលនៃការសម្រេចចិត្តនេះ។ បន្ទាប់មក ការប្តឹងឧទ្ធរណ៍របស់អ្នកនឹងអនុវត្តទៅតាមរយៈពេលរបស់ការប្តឹងឧទ្ធរហ៍បែបធម្មតាដូចដែលបានរៀបរាប់នៅខាងលើនៃផ្នែកនេះ។ ប្រសិនបើអ្នកមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តដែលថាការប្តឹងឧទ្ធរណ៍របស់អ្នកមិនស្របតាមល័ក្ខខ័ណ្ឌនៃការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សទេនោះ អ្នកអាចដាក់ពាក្យបណ្តឹងអំពីភាពអយុត្តិធម៌ (file a grievance) បាន។

នៅពេលដែលគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកបានដោះស្រាយសំណើរបស់អ្នកសម្រាប់ការប្តឹងឧទ្ធរណ៍បែបឆាប់រហ័សនោះ គម្រោងថែទាំសុខភាពផ្លូវចិត្តនឹងជូនដំណឹងដល់អ្នក និងភាគីដែលពាក់ព័ន្ធទាំងអស់ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

# ដំណើរការនៃការឡើងសវនាការថ្នាក់រដ្ឋ

## តើការឡើងសវនាការថ្នាក់រដ្ឋគឺជាអ្វី?

ការឡើងសវនាការថ្នាក់រដ្ឋ (State Hearing) គឺជាការពិនិត្យឡើងវិញដោយឯករាជ្យ ហើយធ្វើឡើងដោយចៅក្រមផ្នែកច្បាប់រដ្ឋបាលដែលធ្វើការនៅនាយកដ្ឋានសេវាកម្មសង្គមនៃរដ្ឋ California (California Department of Social Services) ដើម្បីធានាថាអ្នកទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលអ្នកមានសិទ្ធិទទួលបានជាផ្នែកមួយនៃកម្មវិធីធានារ៉ាប់រង Medi-Cal ។ អ្នកក៏អាចនឹងចូលទៅកាន់គេហទំព័ររបស់នាយកដ្ឋានសេវាកម្មសង្គមនៃរដ្ឋ California បានតាមរយៈ https://www.cdss.ca.gov/hearing-requests សម្រាប់ធនធានបន្ថែម។

## តើសិទ្ធិឡើងសវនាការថ្នាក់រដ្ឋរបស់ខ្ញុំមានអ្វីខ្លះ?

អ្នកមានសិទ្ធិក្នុងការ៖

- ឡើងសវនាការនៅចំពោះមុខចៅក្រមផ្នែកច្បាប់រដ្ឋបាល (ហៅថាជាការឡើងសវនាការថ្នាក់រដ្ឋ (State Hearing) ផងដែរ)។
- ទទួលបានព័ត៌មានអំពីរបៀបស្នើសុំឡើងសវនាការថ្នាក់រដ្ឋ។
- ទទួលបានព័ត៌មានអំពីច្បាប់ដែលបញ្ជាក់អំពីការមានអ្នកតំណាងនៅពេលឡើងសវនាការថ្នាក់រដ្ឋ។
- បន្តទទួលបានអត្ថប្រយោជន៍របស់អ្នកនៅពេលមានការស្នើសុំពីអ្នក ក្នុងអំឡុងពេលដំណើរការនៃការឡើងសវនាការថ្នាក់រដ្ឋ ប្រសិនបើអ្នកស្នើសុំឱ្យមានការឡើងសវនាការថ្នាក់រដ្ឋក្នុងអំឡុងពេលវេលាដែលបានតម្រូវចាំបាច់ឱ្យស្នើសុំនោះ។

## តើខ្ញុំអាចដាក់ពាក្យបណ្ដឹងសម្រាប់ឡើងសវនាការថ្នាក់រដ្ឋបាននៅពេលណា?

អ្នកអាចដាក់ពាក្យបណ្ដឹងសម្រាប់ឡើងសវនាការថ្នាក់រដ្ឋ (State Hearing) បាន ក្នុងស្ថានភាពណាមួយខាងក្រោមនេះ៖

- អ្នកបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ (file an appeal) ហើយបានទទួលលិខិតដោះស្រាយបណ្ដឹងឧទ្ធរណ៍ដែលប្រាប់អ្នកថាគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកបដិសេធសំណើបណ្ដឹងឧទ្ធរណ៍របស់អ្នក។
- ការប្ដឹងអំពីភាពយុត្តិធម៌ (grievance) ឬការប្ដឹងឧទ្ធរណ៍ ឬក៏ការប្ដឹងឧទ្ធារណ៍បែបឆាប់រហ័ស (expedited appeal) របស់អ្នកមិនត្រូវបានដោះស្រាយទាន់ពេលវេលាទេនោះ។

## តើខ្ញុំស្នើសុំឡើងសវនាការថ្នាក់រដ្ឋបានដោយរបៀបណា?

អ្នកអាចស្នើសុំឡើងសវនាការថ្នាក់រដ្ឋបាន៖

- <u>តាមអនឡាញ</u> នៅលើគេហទំព័រ៖ https://acms.dss.ca.gov/acms/login.request.do
- <u>ជាលាយលក្ខណ៍អក្សរ៖</u> ដាក់បញ្ជូនសំណើរបស់អ្នកទៅកាន់នាយកដ្ឋានផ្នែកសុខុមាលភាពរបស់ខោនធី តាមរយៈអាស័យដ្ឋានដែលមាននៅលើសេចក្ដីជូនដំណឹងអំពីការសម្រេចឈប់ផ្ដល់អត្ថប្រយោជន៍ (Notice of

Adverse Benefit Determination) ឬផ្ញើឯកសារតាមសំបុត្រទៅកាន់៖

California Department of Social Services
State Hearings Division
PO Box 944243, Mail Station 9-17-37
Sacramento, CA 94244-2430

ឬតាមទូរសារ (ហ្វេក) ទៅកាន់លេខ៖ **916-651-5210** ឬ **916-651-2789**។

អ្នកក៏អាចស្នើសុំឡើងសវនាការថ្នាក់រដ្ឋ ឬការឡើងសវនាការថ្នាក់រដ្ឋបែបឆាប់រហ័ស (expedited State Hearing) បានផងដែរ៖

- <u>តាមទូរស័ព្ទ</u>៖ ទូរស័ព្ទទៅកាន់ផ្នែកសវនាការថ្នាក់រដ្ឋ (State Hearings Division) ដោយមិនគិតថ្លៃ តាមរយៈលេខ**800-743-8525** ឬ **855-795-0634** ឬទូរស័ព្ទទៅបណ្តាញព័ត៌មានផ្នែកសាកសួរ និងឆ្លើយតបសាធារណៈ (Public Inquiry and Response line) ដោយមិនគិតថ្លៃ តាមរយៈលេខ **800-952-5253** ឬសម្រាប់អ្នកថ្លង់ (TDD) តាម  រយៈលេខ **800-952-8349**។

**តើមានកាលកំណត់ដើម្បីស្នើសុំឡើងសវនាការថ្នាក់រដ្ឋ ដែរឬទេ?**

ចាស/បាទ អ្នកមានពេលត្រឹមតែ 120 ថ្ងៃប៉ុណ្ណោះ ដើម្បីស្នើសុំឡើងសវនាការថ្នាក់រដ្ឋ។ រយៈពេល 120 ថ្ងៃនេះចាប់ផ្តើមនៅថ្ងៃបន្ទាប់ពីគម្រោងថែទាំសុខភាពផ្លូវចិត្តផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការសម្រេចចិត្តនៃការប្តឹងឧទ្ធរណ៍របស់ខ្លួនដោយផ្ទាល់ ឬមួយថ្ងៃបន្ទាប់ពីកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ដែលបានបោះត្រានៅលើស្រោមសំបុត្រការជូនដំណឹងរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តអំពីការសម្រេចចិត្តនៃការប្តឹងឧទ្ធរណ៍។

ប្រសិនបើអ្នកមិនបានទទួលសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ (Notice of Adverse Benefit Determination) ទេនោះ អ្នកអាចដាក់ពាក្យបណ្តឹងឡើងសវនាការថ្នាក់រដ្ឋនៅពេលណាក៏បាន។

**តើខ្ញុំអាចបន្តទទួលសេវាកម្មបានដែរឬទេ ខណៈពេលដែលខ្ញុំកំពុងរង់ចាំការកាត់សេចក្តីពីសវនាការថ្នាក់រដ្ឋនោះ?**

ប្រសិនបើអ្នកកំពុងទទួលបានសេវាកម្មដែលមានការអនុញ្ញាតនាពេលឥឡូវនេះ ហើយអ្នកចង់បន្តទទួលបានសេវាកម្មនេះ ខណៈពេលដែលអ្នករង់ចាំការកាត់សេចក្តីសវនាការថ្នាក់រដ្ឋនោះ អ្នកត្រូវតែស្នើសុំឡើងសវនាការថ្នាក់រដ្ឋក្នុងអំឡុងពេល 10 ថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) ទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចឈប់ផ្តល់អត្ថប្រយោជន៍ ឬមុនកាលបរិច្ឆេទដែលគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកនិយាយថាសេវាកម្មនឹងត្រូវបញ្ឈប់ ឬកាត់បន្ថយ។ នៅពេលអ្នកស្នើសុំឡើងសវនាការថ្នាក់រដ្ឋ អ្នកត្រូវតែនិយាយថាអ្នកចង់បន្តទទួលបានសេវាកម្មផ្សេងៗ ក្នុងអំឡុងពេលដំណើរការនៃការឡើងសវនាការថ្នាក់រដ្ឋនោះ។

ប្រសិនបើអ្នកស្នើសុំការបន្តផ្តល់សេវាកម្មផ្សេងៗ ហើយការសម្រេចចិត្តចុងក្រោយអំពីសវនាការថ្នាក់រដ្ឋបញ្ជាក់អំពីការសម្រេចចិត្តក្នុងការកាត់បន្ថយ ឬបញ្ឈប់សេវាកម្មដែលអ្នកកំពុងទទួលបានមែននោះ អ្នកអាចនឹងតម្រូវចាំបាច់ត្រូវបង់ថ្លៃសេវាកម្មដែលបានផ្តល់ជូន ខណៈពេលកំពុងរង់ចាំឡើងសវនាការថ្នាក់រដ្ឋ។

**តើការសម្រេចចិត្តអំពីសវនាការថ្នាក់រដ្ឋរបស់ខ្ញុំនឹងត្រូវធ្វើឡើងនៅពេលណា?**

បន្ទាប់ពីអ្នកស្នើសុំឡើងសវនាការថ្នាក់រដ្ឋរួចនោះ អាចចំណាយពេលរហូតដល់ 90 ថ្ងៃ ដើម្បីសម្រេចករណីរបស់អ្នក ហើយផ្ញើចម្លើយមកអ្នកវិញ។

**តើខ្ញុំអាចឡើងសវនាការថ្នាក់រដ្ឋបានលឿនជាងនេះ ដែរឬទេ?**

ប្រសិនបើអ្នកគិតថាការរង់ចាំរយៈយូរដូចនេះនឹងមានគ្រោះថ្នាក់ដល់សុខភាពរបស់អ្នកនោះ អ្នកប្រហែលជាអាចទទួលបានចម្លើយក្នុងរយៈពេល បីថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ)។ ស្នើឱ្យគ្រូពេទ្យ ឬអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តរបស់អ្នកសរសេរលិខិតមួយជូនអ្នក។ អ្នកក៏អាចសរសេរលិខិតនេះដោយខ្លួនឯងបានផងដែរ។ លិខិតនេះត្រូវតែពន្យល់ជាលម្អិតថាការរង់ចាំរហូតដល់ 90 ថ្ងៃសម្រាប់ការកាត់សេចក្តីករណីរបស់អ្នក នឹងធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត សុខភាព ឬសមត្ថភាពក្នុងការទទួលបានការរក្សា ឬការទទួលបានមកវិញនូវដំណើរការក្នុងការរស់នៅដែលខ្ពស់បំផុតនោះ។ បន្ទាប់មក ត្រូវប្រាកដថាអ្នកស្នើសុំឡើង "សវនាការបែបឆាប់រហ័ស (expedited hearing)" ហើយផ្តល់លិខិតនោះជាមួយនឹងសំណើឡើងសវនាការរបស់អ្នក។

ផ្នែកសវនាការថ្នាក់រដ្ឋរបស់នាយកដ្ឋានសេវាកម្មសង្គម (Department of Social Services, State Hearings Division) នឹងពិនិត្យសំណើរបស់អ្នកសម្រាប់ការឡើងសវនាការថ្នាក់រដ្ឋបែបឆាប់រហ័សនេះ ហើយសម្រេចថាតើសំណើនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ។ ប្រសិនបើសំណើនៃការឡើងសវនាការបែបឆាប់រហ័សរបស់អ្នកបានទទួលការអនុញ្ញាតនោះ សវនាការនឹងត្រូវធ្វើឡើង ហើយការកាត់សេចក្តីទៅលើសវនាការនឹងត្រូវចេញក្នុងរយៈពេល បីថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) ចាប់តាំងពីថ្ងៃដែលផ្នែកសវនាការថ្នាក់រដ្ឋបានទទួលសំណើរបស់អ្នក។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

# សេចក្តីណែនាំទុកជាមុន

## តើសេចក្តីណែនាំទុកជាមុនគឺជាអ្វី?

អ្នកមានសិទ្ធិក្នុងការមានសេចក្តីណែនាំទុកជាមុន (advance directive)។ សេចក្តីណែនាំទុកជាមុនគឺជាការណែនាំជាលាយលក្ខណ៍អក្សរអំពីការថែទាំសុខភាពរបស់អ្នក ដែលមានការទទួលស្គាល់ក្រោមច្បាប់របស់រដ្ឋ California។ សេចក្តីណែនាំនេះរួមមានព័ត៌មានដែលបញ្ជាក់អំពីរបៀបដែលអ្នកចង់ទទួលការថែទាំសុខភាព ឬនិយាយថាតើការសម្រេចចិត្តអ្វីទៅដែលអ្នកចង់ធ្វើ ប្រសិនបើឬនៅពេលដែលអ្នកមិនអាចនិយាយដោយខ្លួនឯងបាន។ ពេលខ្លះអ្នកអាចនឹងស្តាប់ឮថាសេចក្តីណែនាំទុកជាមុននេះត្រូវបានពិពណ៌នាថាជាបណ្តាំណែនាំ (living will) ឬការផ្តល់សិទ្ធិសម្រេចចិត្តទាក់ទងទៅនឹងសុខភាពរបស់អ្នកជូនទៅនរណាម្នាក់ ក្នុងករណីដែលអ្នកក្លាយទៅជាពិការឬមិនដឹងខ្លួន (durable power of attorney)។

ច្បាប់របស់រដ្ឋ California កំណត់ថាសេចក្តីណែនាំទុកជាមុនគឺជាការណែនាំអំពីការថែទាំសុខភាពរបស់បុគ្គលម្នាក់ ជាលក្ខណៈផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឬក៏ជាលិខិតផ្តល់សិទ្ធិសម្រេចចិត្ត (ឯកសារជាលាយលក្ខណ៍អក្សរដែលផ្តល់ការអនុញ្ញាតឱ្យនរណាម្នាក់ដើម្បីធ្វើការសម្រេចចិត្តជូនអ្នក (power of attorney))។ គម្រោងថែទាំសុខភាពផ្លូវចិត្តទាំងអស់គឺតម្រូវចាំបាច់ឱ្យមានគោលការណ៍អំពីសេចក្តីណែនាំទុកជាមុននេះទុកជាស្រេច។ គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកគឺតម្រូវចាំបាច់ឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរលើគោលការណ៍អំពីសេចក្តីណែនាំជាមុននេះ របស់គម្រោងថែទាំសុខភាពផ្លូវចិត្ត និងការពន្យល់អំពីច្បាប់របស់រដ្ឋ (ស្តេត) ប្រសិនបើមានការស្នើសុំព័ត៌មាននេះ។ ប្រសិនបើអ្នកចង់ស្នើសុំព័ត៌មាននេះ អ្នកគួរតែទូរស័ព្ទទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

សេចក្តីណែនាំទុកជាមុនត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឱ្យមនុស្សទាំងឡាយមានការគ្រប់គ្រងទៅលើការព្យាបាលរបស់ពួកគេផ្ទាល់ ជាពិសេសនៅពេលដែលពួកគេមិនអាចផ្តល់ការណែនាំអំពីការថែទាំផ្ទាល់ខ្លួនរបស់ពួកគេបាននោះ។ សេចក្តីណែនាំនេះគឺជាឯកសារផ្លូវច្បាប់ដែលអនុញ្ញាតឱ្យមនុស្សទាំងឡាយបញ្ជាក់ទុកជាមុននូវអ្វីដែលពួកគេចង់បាន ប្រសិនបើពួកគេមិនអាចធ្វើការសម្រេចចិត្តលើការថែទាំសុខភាពនានាបាននោះ។ នេះអាចរាប់បញ្ចូលទាំងសិទ្ធិក្នុងការទទួលយក ឬបដិសេធការព្យាបាលផ្នែកពេទ្យ ឬការវះកាត់ ឬក៏ធ្វើការជ្រើសរើសការថែទាំសុខភាពផ្សេងទៀត ផងដែរ។ នៅក្នុងរដ្ឋ California សេចក្តីណែនាំទុកជាមុន មានពីរផ្នែកៈ

- ការតែងតាំងភ្នាក់ងាររបស់អ្នក (ជាមនុស្សម្នាក់) ក្នុងការធ្វើការសម្រេចចិត្តអំពីការថែទាំសុខភាពរបស់អ្នក និង
- ការណែនាំអំពីការថែទាំសុខភាពផ្ទាល់ខ្លួនរបស់អ្នក

អ្នកអាចនឹងទទួលបានបែបបទសម្រាប់សេចក្តីណែនាំជាមុននេះពីគម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នក ឬតាមអនឡាញ។ នៅក្នុងរដ្ឋ California អ្នកមានសិទ្ធិផ្តល់សេចក្តីណែនាំទុកជាមុនដល់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងអស់របស់អ្នក។ អ្នកក៏មានសិទ្ធិផ្លាស់ប្តូរ ឬលុបចោលនូវសេចក្តីណែនាំទុកជាមុនរបស់អ្នកនេះបានគ្រប់ពេល ផងដែរ។

ប្រសិនបើអ្នកមានសំណួរអំពីច្បាប់របស់រដ្ឋ California ទាក់ទងទៅនឹងតម្រូវការទាំងឡាយអំពីសេចក្តីណែនាំទុកជាមុននេះ អ្នកអាចផ្ញើលិខិតមួយទៅកាន់៖

California Department of Justice
Attn: Public Inquiry Unit,
P.O. Box 944255
Sacramento, CA 94244-2550

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។

## សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នកទទួលបានអត្ថប្រយោជន៍

### តើសិទ្ធិរបស់ខ្ញុំ ក្នុងនាមជាអ្នកទទួលសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស មានអ្វីខ្លះ?

ក្នុងនាមជាបុគ្គលម្នាក់ដែលមានសិទ្ធិចូលរួមក្នុងកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អ្នកមានសិទ្ធិក្នុងការទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលជាការចាំបាច់ទៅតាមផ្នែកពេទ្យ (medically necessary) ពីគម្រោងថែទាំសុខភាពផ្លូវចិត្ត។ នៅពេលទទួលបានសេវាកម្មទាំងនេះ អ្នកមានសិទ្ធិក្នុងការៈ

- មានការគិតគូទៅលើអ្នកដោយការគោរពផ្ទាល់ខ្លួន និងគោរពចំពោះសេចក្តីថ្លៃថ្នូរ និងការសម្ងាត់របស់អ្នក។
- ទទួលបានព័ត៌មានអំពីជម្រើសនៃការព្យាបាលផ្សេងៗដែលមានសម្រាប់ប្រើប្រាស់ ហើយមានការពន្យល់តាមរបៀបមួយដែលអ្នកអាចយល់បាន។
- ចូលរួមក្នុងការសម្រេចចិត្តទាក់ទងទៅនឹងការថែទាំផ្នែកសុខភាពផ្លូវចិត្តរបស់អ្នក រួមទាំងសិទ្ធិក្នុងការបដិសេធការព្យាបាលផងដែរ។
- មានសេរីភាពពីការរឹតត្បិតផ្សេងៗ ឬភាពនៅដាច់ពីគេឯងណាមួយដែលប្រើប្រាស់ជាមធ្យោបាយសម្រាប់ការបង្ខិតបង្ខំ ឬការដាក់វិន័យ ឬជាភាពងាយស្រួល (សម្រាប់អ្នកដទៃពីព្រោះពួកគេមិនចង់ដោះស្រាយជាមួយនឹងអ្នក) ឬការដាក់ទណ្ឌកម្ម ឬក៏ការសងសឹកចំពោះការប្រើប្រាស់ការរឹតត្បិតផ្សេងៗ និងភាពនៅដាច់ពីគេឯងនេះ។
- ស្នើសុំ និងទទួលបានច្បាប់ចម្លងនៃកំណត់ត្រាផ្នែកពេទ្យរបស់អ្នក ហើយនិងស្នើសុំឱ្យមានការផ្លាស់ប្តូរ ឬកែតម្រូវទៅលើព័ត៌មានទាំងនោះ ប្រសិនបើចាំបាច់។
- ទទួលបានព័ត៌មាននៅក្នុងសៀវភៅណែនាំនេះអំពីសេវាកម្មទាំងឡាយដែលចេញថ្លៃចំណាយជូនដោយគម្រោងថែទាំសុខភាពផ្លូវចិត្ត កាតព្វកិច្ចផ្សេងទៀតនៃគម្រោងថែទាំសុខភាពផ្លូវចិត្ត និងសិទ្ធិទាំងឡាយរបស់អ្នក ដូចដែលបានពិពណ៌នានៅទីនេះ។ អ្នកក៏មានសិទ្ធិទទួលបានព័ត៌មាននេះ និងព័ត៌មានផ្សេងទៀតដែលផ្តល់ជូនអ្នកដោយគម្រោងថែទាំសុខភាពផ្លូវចិត្តក្នុងទម្រង់មួយដែលងាយស្រួលនឹងយល់ និងស្របទៅតាមច្បាប់ស្តីពីពិការភាពរបស់អាមេរិក (American Disabilities Act) ។ ជាឧទាហរណ៍ នេះមានន័យថា គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែធ្វើឱ្យព័ត៌មានជាលាយលក្ខណ៍អក្សររបស់គម្រោងមានជាភាសាដែលប្រើប្រាស់ដោយអ្នកទទួលបានអត្ថប្រយោជន៍នៃគម្រោងថែទាំសុខភាពផ្លូវចិត្តដែលមានចំនួនយ៉ាងតិច ប្រាំភាគរយ ឬ 3,000 នាក់ គិតយកចំនួនណាមួយដែលតិចជាង ហើយនិងផ្តល់សេវាកម្មផ្នែកបកប្រែផ្ទាល់មាត់ដោយមិនគិតថ្លៃសម្រាប់អ្នកដែលនិយាយភាសាផ្សេងទៀត។ ចំណុចនេះក៏មានន័យថាគម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែផ្តល់ឯកសារទាំងឡាយសម្រាប់មនុស្សដែលមានតម្រូវការពិសេសផងដែរ ដូចជាជនពិការភ្នែក ឬមើលមិនសូវឃើញច្បាស់ ឬក៏អ្នកដែលមានបញ្ហាក្នុងការអាន ផងដែរ។
- ទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសផ្សេងៗពីគម្រោងថែទាំសុខភាពផ្លូវចិត្តដែលអនុវត្តតាមកិច្ចសន្យារបស់ខ្លួនជាមួយរដ្ឋ (ស្តេត) សម្រាប់ការផ្តល់សេវាកម្មផ្សេងៗ ការធានាបាននូវសមត្ថភាពនិងសេវាកម្មគ្រប់គ្រាន់ ការសម្របសម្រួល និងការបន្តការថែទាំ ហើយនិងការចេញថ្លៃចំណាយនិងការអនុញ្ញាតឱ្យផ្តល់សេវាកម្មផ្សេងៗ ផងដែរ។ មានការតម្រូវចាំបាច់ឱ្យគម្រោងថែទាំសុខភាពផ្លូវចិត្តៈ

- ជួល ឬត្រូវមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពគ្រប់គ្រាន់ដើម្បីធ្វើឱ្យប្រាកដថា អ្នកទទួលបានអត្ថប្រយោជន៍ដែលមានសិទ្ធិប្រើប្រាស់កម្មវិធីធានារ៉ាប់រង Medi-Cal ទាំងអស់ ហើយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសនោះអាចទទួលបានសេវាកម្មទាំងនេះក្នុងលក្ខណៈទាន់ពេលវេលា។
- ចេញថ្លៃចំណាយសម្រាប់អ្នកទៅលើសេវាកម្មទាំងឡាយណាដែលជាការចាំបាច់ទៅតាមផ្នែកពេទ្យ ហើយដែលនៅក្រៅបណ្តាញ ក្នុងលក្ខណៈទាន់ពេលវេលា ប្រសិនបើគម្រោងថែទាំសុខភាពផ្លូវចិត្តមិនមានបុគ្គលិក ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពជាប់កិច្ចសន្យាណាដែលអាចផ្តល់សេវាកម្មបានទេនោះ។ "អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពក្រៅបណ្តាញ (Out-of-network provider)" មានន័យថាជាអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពមួយដែលមិនមានឈ្មោះនៅក្នុងបញ្ជីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តទេ។ គម្រោងថែទាំសុខភាពផ្លូវចិត្តត្រូវតែប្រាកដថាអ្នកមិនបង់ប្រាក់អ្វីបន្ថែមសម្រាប់ការទៅជួបពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពក្រៅបណ្តាញនោះឡើយ។
- ត្រូវប្រាកដថាអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយមានការបណ្តុះបណ្តាលក្នុងការផ្តល់សេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយនោះយល់ព្រមក្នុងការរ៉ាប់រង។
- ត្រូវប្រាកដថាសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេសដែលគម្រោងថែទាំសុខភាពផ្លូវចិត្តមានចេញថ្លៃចំណាយជូនគឺមានបរិមាណ និងរយៈពេល ហើយនិងវិសាលភាព (កម្រិត) គ្រប់គ្រាន់ដើម្បីបំពេញតម្រូវការនានារបស់អ្នកទទួលបានអត្ថប្រយោជន៍ទាំងឡាយដែលមានសិទ្ធិប្រើប្រាស់កម្មវិធីធានារ៉ាប់រង Medi-Cal។ ចំណុចនេះរួមមានទាំងការធ្វើឱ្យប្រាកដថាប្រព័ន្ធសម្រាប់ការយល់ព្រមទៅលើការបង់ប្រាក់ចំពោះសេវាកម្មផ្សេងៗរបស់គម្រោងថែទាំសុខភាពផ្លូវចិត្តនោះ គឺផ្អែកទៅលើការចាំបាច់ទៅតាមផ្នែកពេទ្យ ហើយនិងធ្វើឱ្យប្រាកដថាមានការប្រើប្រាស់លក្ខខ័ណ្ឌនៃការចាំបាច់ទៅតាមផ្នែកពេទ្យនេះដោយយុត្តិធម៌។
- ត្រូវប្រាកដថាអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយរបស់ខ្លួនធ្វើការវាយតម្លៃគ្រប់គ្រាន់ចំពោះមនុស្សដែលអាចនឹងទទួលបានសេវាកម្ម ហើយថាពួកគេសហការជាមួយនឹងមនុស្សដែលនឹងទទួលបានសេវាកម្មផ្សេងៗដើម្បីបង្កើតគោលដៅនានាសម្រាប់ការព្យាបាល និងសេវាកម្មដែលនឹងត្រូវផ្តល់ជូន។
- ផ្តល់មតិទីពីរពីអ្នកជំនាញផ្នែកថែទាំសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងបណ្តាញរបស់គម្រោងថែទាំសុខភាពផ្លូវចិត្ត ឬអ្នកជំនាញម្នាក់ដែលនៅខាងក្រៅបណ្តាញ ដោយមិនគិតថ្លៃបន្ថែមពីអ្នកទេ ប្រសិនបើអ្នកស្នើសុំចំណុចនេះ។
- សម្របសម្រួលសេវាកម្មទាំងឡាយដែលគម្រោងនេះផ្តល់ជូន ជាមួយនឹងសេវាកម្មទាំងឡាយដែលផ្តល់ជូនអ្នកតាមរយៈគម្រោងថែទាំសុខភាពក្រោមការគ្រប់គ្រងរប

សកម្មវិធីធានារ៉ាប់រង Medi-Cal ឬជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកការព្យាបាលទូទៅរបស់អ្នក ប្រសិនបើចាំបាច់ ហើយត្រូវប្រាកដថាការសម្ងាត់របស់អ្នកត្រូវបានការពារ ដូចដែលបានបញ្ជាក់នៅក្នុងច្បាប់ទាំងឡាយរបស់រដ្ឋាភិបាលស្តីពីការសម្ងាត់នៃព័ត៌មានផ្នែកសុខភាព។
    - ផ្តល់ការថែទាំទាន់ពេលវេលា រួមទាំងសេវាកម្មដែលមានផ្តល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ នៅពេលដែលជាការចាំបាច់ទៅតាមផ្នែកពេទ្យ ដើម្បីព្យាបាលបញ្ហាផ្នែកសតិបន្ទាន់ ឬក៏ដោះស្រាយបញ្ហា ឬវិបត្តិបន្ទាន់។
    - ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ (ស្តេត) ក្នុងការលើកទឹកចិត្តដល់ការផ្តល់សេវាកម្មតាមលក្ខណៈមួយដែលប្រកបដោយការយល់ដឹងផ្នែកវប្បធម៌ ជូនដល់ប្រជាជនទាំងអស់ រួមទាំងអ្នកដែលមិនសូវមានជំនាញផ្នែកភាសាអង់គ្លេស ហើយនិងអ្នកដែលមានប្រវត្តិវប្បធម៌ និងជាតិសាសន៍ផ្សេងៗគ្នា ផងដែរ។
- គម្រោងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកគឺតម្រូវចាំបាច់ឱ្យអនុវត្តតាមច្បាប់របស់រដ្ឋាភិបាល និងរបស់រដ្ឋ (ស្តេត) ទាំងឡាយណាដែលអាចអនុវត្តបាន (ដូចជា៖ ចំណងជើងទី VI នៃច្បាប់សិទ្ធិរបស់ប្រជាពលរដ្ឋចេញនៅឆ្នាំ 1964 ដែលបានអនុវត្តដោយបទប្បញ្ញត្តិនៅ 45 CFR ផ្នែកទី 80 និងច្បាប់ស្តីពីការរើសអើងអាយុចេញនៅឆ្នាំ 1975 ដែលបានអនុវត្តដោយបទប្បញ្ញត្តិនៅ 45 CFR ផ្នែក 91 និងច្បាប់ការធ្វើឱ្យរាងកាយនិងអារម្មណ៍បានប្រសើរឡើងវិញចេញនៅឆ្នាំ 1973 និងចំណងជើង IX នៃការកែប្រែការអប់រំចេញនៅឆ្នាំ 1972 (ទាក់ទងទៅនឹងកម្មវិធី និងសកម្មភាពអប់រំផ្សេងៗ) និងចំណងជើង II និង III នៃច្បាប់ជនពិការអាមេរិក) ហើយនិងផ្នែកទី 1557 នៃច្បាប់ការពារអ្នកជម្ងឺ និងការថែទាំដែលមានតម្លៃសមរម្យ ក៏ដូចជាសិទ្ធិនានាដែលមានពិពណ៌នានៅទីនេះ។ ពោលគឺ អ្នកគួរតែទទួលបានការព្យាបាល ហើយត្រូវតែមិនមានការរើសអើង។
- អ្នកអាចនឹងមានសិទ្ធិបន្ថែមទៀតនៅក្រោមច្បាប់របស់រដ្ឋ (ស្តេត) អំពីការព្យាបាលផ្នែកសុខភាពផ្លូវចិត្ត។ ប្រសិនបើអ្នកចង់ទាក់ទងទៅកាន់អ្នកគាំទ្រមតិអំពីសិទ្ធិរបស់អ្នកជំងឺ (Patients’ Rights Advocate) នៃខោនធីរបស់អ្នក អ្នកអាចធ្វើដូច្នេះបានតាមរយៈ៖ *[mental health plan to Add Patient’s Rights’ Contact Information]។

## តើទំនួលខុសត្រូវរបស់ខ្ញុំ ក្នុងនាមជាអ្នកទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស មានអ្វីខ្លះ?

ក្នុងនាមជាអ្នកទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តឯកទេស អ្នកមានទំនួលខុសត្រូវក្នុងការ៖
- អានសៀវភៅណែនាំអ្នកទទួលបានអត្ថប្រយោជន៍នេះ និងឯកសារព័ត៌មានសំខាន់ៗផ្សេងទៀតពីគម្រោងថែទាំសុខភាពផ្លូវចិត្តដោយប្រុងប្រយ័ត្ន។ ឯកសារទាំងនេះនឹងជួយអ្នកឱ្យយល់ថាតើសេវាកម្មណាខ្លះដែលមានផ្តល់ជូន និងរបៀបទទួលបានការព្យាបាល ប្រសិនបើអ្នកត្រូវការការព្យាបាលនោះ។
- ទៅទទួលការព្យាបាលរបស់អ្នកតាមការណាត់។ អ្នកនឹងទទួលបានលទ្ធផលល្អបំផុត ប្រសិនបើអ្នកសហការជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ដើម្បីបង្កើតគោលដៅសម្រាប់ការព្យាបាលរបស់អ្នក ហើយអនុវត្តតាមគោលដៅទាំងនោះ។ ប្រសិនបើអ្នកត្រូវការខកខានមិនបានទៅតាមការណាត់ជួបទេនោះ

សូមទូរស័ព្ទទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកយ៉ាងហោចណាស់ 24 ម៉ោងជាមុន ហើយរៀបចំការណាត់ជួបសម្រាប់ថ្ងៃ និងពេលវេលាផ្សេងទៀត។

- នាំយកប័ណ្ណសម្គាល់អត្ថប្រយោជន៍កម្មវិធីធានារ៉ាប់រង Medi-Cal របស់អ្នក (BIC) និងប័ណ្ណសម្គាល់ខ្លួនដែលរូបថត នៅគ្រប់ពេលដែលអ្នកទៅទទួលការព្យាបាល។
- ប្រាប់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ មុនពេលការណាត់ជួបរបស់អ្នក។
- ប្រាប់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នករាល់កង្វល់ផ្នែកសុខភាពរបស់អ្នក។ ការចែករំលែកព័ត៌មានអំពីតម្រូវការផ្សេងៗរបស់អ្នកបានកាន់តែពេញលេញនោះ ការព្យាបាលរបស់អ្នកនឹងកាន់តែជោគជ័យផងដែរ។
- ត្រូវប្រាកដថាសាកសួរទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកនូវសំណួរផ្សេងៗណាដែលអ្នកមាន។ ការដែលអ្នកយល់ដឹងទាំងស្រុងនូវព័ត៌មានទាំងឡាយដែលអ្នកទទួលបានក្នុងអំឡុងពេលការព្យាបាលនោះ គឺជាការសំខាន់ខ្លាំងណាស់។
- អនុវត្តឱ្យបានពេញលេញតាមជំហានសកម្មភាពដែលបានគ្រោងទុក ដែលអ្នក និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកបានយល់ព្រមនោះ។
- ទាក់ទងទៅកាន់គម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីសេវាកម្មរបស់អ្នក ឬប្រសិនបើអ្នកមានបញ្ហាណាមួយជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ហើយដែលអ្នកមិនអាចដោះស្រាយបាន។
- ប្រាប់ទៅដល់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក និងគម្រោងថែទាំសុខភាពផ្លូវចិត្ត ប្រសិនបើអ្នកមានការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ចំណុចនេះរួមមានទាំងអាសយដ្ឋាន លេខទូរស័ព្ទ និងព័ត៌មានផ្នែកសុខភាពផ្សេងទៀតដែលអាចនឹងប៉ះពាល់ដល់សមត្ថភាពរបស់អ្នកក្នុងការចូលរួមក្នុងការព្យាបាល។
- គិតគូទៅលើបុគ្គលិកដែលផ្តល់ការព្យាបាលរបស់អ្នក ដោយការគោរព និងការគួរសម។
- ប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ ឬបទល្មើសណាមួយ សូមរាយការណ៍ករណីនោះ៖
    - នាយកដ្ឋានសេវាកម្មផ្នែកថែទាំសុខភាព (Department of Health Care Services/DHCS) ស្នើសុំឱ្យនរណាម្នាក់ដែលសង្ស័យថាមានការក្លែងបន្លំ ឬការខ្ជះខ្ជាយ ឬក៏ការរំលោភបំពានចំពោះកម្មវិធីធានារ៉ាប់រង Medi-Cal ឱ្យទូរស័ព្ទទៅខ្សែទូរស័ព្ទបន្ទាន់សម្រាប់រាយការណ៍ពីការក្លែងបន្លំចំពោះកម្មវិធីធានារ៉ាប់រង Medi-Cal របស់ DHCS តាមរយៈលេខ **1-800-822-6222**។ ប្រសិនបើអ្នកមានអារម្មណ៍ថានោះគឺជាករណីបន្ទាន់ សូមទូរស័ព្ទទៅកាន់លេខ **911** សម្រាប់ជំនួយជាបន្ទាន់។ ការទូរស័ព្ទទៅនេះគឺមិនគិតថ្លៃទេ ហើយអ្នកដែលទូរស័ព្ទទៅនោះអាចមិនបញ្ចេញឈ្មោះបាន។
    - អ្នកក៏អាចរាយការណ៍អំពីការក្លែងបន្លំ ឬការរំលោភបំពានដែលសង្ស័យបានផងដែរ តាមរយៈអ៊ីម៉ែលទៅកាន់ fraud@dhcs.ca.gov ឬប្រើប្រាស់បែបបទតាមអនឡាញនៅលើគេហទំព័រ http://www.dhcs.ca.gov/individuals/Pages/StopMedi-CalFraud.aspx។

**ព័ត៌មានជាក់លាក់បន្ថែម អំពីគម្រោងថែទាំសុខភាពផ្លូវចិត្ត**

បញ្ចូលព័ត៌មានជាក់លាក់អំពី គម្រោងថែទាំសុខភាពផ្លូវចិត្ត នៅទីនេះ [if any]។